ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៤ លេខ៣៧ ត្រីមាសទី០២ ឆ្នាំ២០២៤

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

## សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៣-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៥៤ ស្តីពី ការបន្ថយឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ **សុខ មូរ** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ឱ្យមកនៅត្រឹមថ្នាក់ពលបាលត្រី ក្របខ័ណ្ឌមន្ត្រីនគរបាល-ជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៥០៣៩ |
| ១៣-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៥៥ ស្តីពី ការបន្ថយឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក **ឃិន គារ** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ឱ្យមកនៅត្រឹមថ្នាក់ពលបាលត្រី ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៥០៤០ |
| ១៤-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៥៦ ស្តីពី ការតែងតាំងមុខតំណែងជាអនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២រូប | ៥០៤១ |
| ១៤-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៥៧ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតចំនួន ២រូប | ៥០៤២ |
| ១៤-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៥៨ ស្តីពី ការបញ្ចប់គោរមងារ ឧកញ៉ា ពីឧកញ៉ា **ឡេង ចាន់ណា** | ៥០៤៣ |
| ១៥-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៥៩ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ដួង វីរ័ត្ន** ពីទីប្រឹក្សាផ្ទាល់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជា-ណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី | ៥០៤៤ |
| ១៥-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦០ ស្តីពី ការតែងតាំង និងផ្តល់ឋានៈលោកជំទាវ **ខង សិរីអមតា** ជាជំនួយការសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក | ៥០៤៥ |
| ១៥-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦១ ស្តីពី និយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដល់លោក **ចិន ខន្តី** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ | ៥០៤៦ |
| ១៦-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦២ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ជា មូរ៉ា** ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | ៥០៤៧ |
| ១៦-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦៣ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ទួន ចែម** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី | ៥០៤៨ |
| ១៦-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូប | ៥០៤៩ |
| ១៦-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម **ហាប់ អូម៉ាលី** | ៥០៥០ |
| ១៦-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ៤អង្គ/រូប | ៥០៥១ |

១៦-៣-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៦៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា និងថ្នាក់ដឹកនាំ បុគ្គលិក ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ៧រូប ៥០៥២

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៥-៣-២០២៤ -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្ដីពី ការផ្ទេរឥណទាន ៥០៥៣

១៥-៣-២០២៤ -អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល ៥០៥៦

១៩-៣-២០២៤ -អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្ដីពី ការផ្ទេរឥណទាន ៥០៨៧

១៥-៣-២០២៤ -អនុក្រឹត្យលេខ ១៦០ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥០៩០

១៥-៣-២០២៤ -អនុក្រឹត្យលេខ ១៦១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥០៩១

១៥-៣-២០២៤ -អនុក្រឹត្យលេខ ១៦២ អនក្រ.តត ស្ដីពី ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា ៥០៩៣

### ២~សេចក្ដីសម្រេច

១៥-៣-២០២៤ -សេចក្ដីសម្រេចលេខ ៥៤ សសរ ស្ដីពី ការកែសម្រួលសមាសភាពក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តព្រះសីហនុ និងខេត្តស្វាយរៀង ៥០៩៦

១៥-៣-២០២៤ -សេចក្ដីសម្រេចលេខ ៥៥ សសរ ស្ដីពី ការកែសម្រួលសមាសភាពក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តកំពត និងខេត្តកណ្ដាល ៥០៩៨

## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥-២-២០២៤ -ប្រកាសលេខ ១០៤ សហវ.ប្រក ស្ដីពី ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៥១០០

### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១០-១០-២០២៣ -ប្រកាសលេខ ៤១០ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាំងម៉ៅ (ខេមបូឌា) ហូមវែរ ឯ.ក បង្កើតរោងចក្រផលិតអំពូលភ្លើង សម្ភារប្រើប្រាស់ក្នុងផ្ទះ បន្ទប់ទឹក និងគ្រឿងបង្គុំ វាំងនន ៥១០៤

១០-១០-២០២៣ -ប្រកាសលេខ ៤១១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រាយម៍ ស្ដេច សឺលូសិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះពីលោហធាតុកែច្នៃ (ផ្ញើរ) ៥១០៧

១០-១០-២០២៣ -ប្រកាសលេខ ៤១២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាប់បែលយូដាប់បែលយូ ធូល អិលអិលស៊ី ឯ.ក បង្កើតរោងចក្រផលិត និងផ្គុំតម្លើងឧបករណ៍ជាង ៥១១០

| | | |
|---|---|---|
| ១០-១០-២០២៣ | -ប្រកាសលេខ ៤១៣ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឃីង មេធល (ខេមបូឌា) ហាដវែរ សឺបផ្លាយ ឯ.ក បង្កើតរោងចក្រផលិតសម្ភារប្រើប្រាស់ក្នុងផ្ទះគ្រប់ប្រភេទ រទេះរុញទំនិញ និងផលិតផលប្លាស្ទិក | ៥១១៣ |
| ១០-១០-២០២៣ | -ប្រកាសលេខ ៤១៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីលីត អ៊ិនធើប្រាយ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ | ៥១១៦ |
| ១០-១០-២០២៣ | -ប្រកាសលេខ ៤១៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេអេច បេស ហ្វេតស៍ មេនូហ្វេកឆឺរីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតកាបូប និងសាឡុគ្រប់ប្រភេទ | ៥១១៩ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤១៧ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គីរីន ខ្លូស៊ីង ហ្គាម៉ិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ | ៥១២២ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤១៨ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហៃ ឡុង ហ្វា អ៊ិស្គ ឌីវេឡុបម៉ិន (ខេមបូឌា) បង្កើតរោងចក្រប៉ាក់ និងបោះពុម្ពសម្លៀកបំពាក់ | ៥១២៥ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤១៩ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជុងកាង ស្ទីល ស្ត្រាក់ឈ័រ (ខេមបូឌា) បង្កើតរោងចក្រកែច្នៃដែកធុនធ្ងន់ | ៥១២៨ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤២១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អិល.វ៉ាយ.ហ្វ៊ូតវែរ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតស្បែកជើងគ្រប់ប្រភេទ | ៥១៣១ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤២២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វាញ ហ្វ្លីង (ខេមបូឌា) បង្កើតរោងចក្រផលិតក្ដារកុងប្លាកេ និងក្ដារបន្ទះ | ៥១៣៤ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤២៣ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូអេសថ៍ ហ្គាម៉ិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ | ៥១៣៧ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤២៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាន ជៀ ហាវ នីតធីង ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ | ៥១៤០ |
| ១១-១០-២០២៣ | -ប្រកាសលេខ ៤២៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូសិន អឺភែរឹល មេនូហ្វេកឆឺរីង ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ បោកគក់ និងបោះពុម្ព | ៥១៤៣ |
| ១៦-១០-២០២៣ | -ប្រកាសលេខ ៤៣៦ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូភើរ នីតធីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតស្រោមជើង ស្រោមដៃ អាវចាក់ និងសម្លៀកបំពាក់ | ៥១៤៦ |
| ១៦-១០-២០២៣ | -ប្រកាសលេខ ៤៣៧ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អាតធីវើស្ស (ខេមបូឌា) ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ | ៥១៤៩ |
| ១៧-១០-២០២៣ | -ប្រកាសលេខ ៤៤៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ផៅវ័រ ក្រោន ហ្វ៊ូតវែរ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង | ៥១៥២ |

| | | |
|---|---|---|
| ១៧-១០-២០២៣ | -ប្រកាសលេខ ៤៤៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជ័នធី ប្រាយធីង ឯ.ក បង្កើតរោងចក្រផ្គុំតម្លើងអំពូលភ្លើងពណ៌លម្អគ្រប់ប្រភេទ | ៥១៥៥ |
| ១៩-១០-២០២៣ | -ប្រកាសលេខ ៤៥៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក បង្កើតសាខារោងចក្រកាត់ដេរសម្លៀកបំពាក់ | ៥១៥៨ |
| ១៩-១០-២០២៣ | -ប្រកាសលេខ ៤៥៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ធីអិកស៍ ហ្វ៊ូដ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតមី និងគុយទាវ | ៥១៦១ |
| ១៩-១០-២០២៣ | -ប្រកាសលេខ ៤៥៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាលី ភែកឃីជីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតសម្ភារវេចខ្ចប់គ្រប់ប្រភេទពីប្លាស្ទិក | ៥១៦៤ |

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/២៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បន្ថយឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ **សុខ ឫទ្ធិ** អត្តលេខ ៣៤៩០៨ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ឲ្យមកនៅត្រឹមថ្នាក់ **ពលបាលត្រី** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

(ហត្ថលេខា)

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣៩៩.២៤០៣.២៥៤

បានយកសេចក្តីគោរពជូនបន្ត
បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៥៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បន្ថយឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក **ឃិន គារ** អត្តលេខ ០១០២៦ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ឲ្យមកនៅត្រឹមថ្នាក់ **ពលបាលត្រី** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ស.ជ.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ពរស.២៤០៣.៤៥៥

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៥៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរាគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងជាអនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២រូប ៖

១-ឯកឧត្តម **ស្រី ឧុឌ្សី**

២-លោកជំទាវ **ខិន សូនាថ**

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧០.៤៥៣.៤៥៦

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៧២៤/២៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៣០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : លើកលែងទោសឱ្យទណ្ឌិតចំនួន ២រូប ដែលមានរាយនាមដូចខាងក្រោម៖

១-ឈ្មោះ **ខុយ ផា** ភេទប្រុស កើតឆ្នាំ១៩៦២ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ៦ខែ និងពិន័យជាប្រាក់ចំនួន ២ លានរៀល តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៣៩៩ "u" ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ របស់តុលាការកំពូល។

២-ឈ្មោះ **ផា តឿ** ឬ **ផា ទឿ** ភេទប្រុស កើតឆ្នាំ១៩៩២ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ៦ខែ និងពិន័យជាប្រាក់ចំនួន ២ លានរៀល តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៣៩៩ "u" ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ របស់តុលាការកំពូល។

**មាត្រា២**: សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ព.រ.ស.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចរល.២៤០៧.២៥៧

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

**បញ្ចប់គោរមងារ** :

**ឧកញ៉ា**

ពីឧកញ៉ា **ឡេង ចាន់ណា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៤
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ជរល.២៤០៣.៤៥៤

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ខន់ វិសុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់មុខតំណែងឯកឧត្តម **ដួង ទីរ័ត្ន** ពីទីប្រឹក្សាផ្ទាល់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី**។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៦៧.៤០៣.៤៥៩

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៦០

យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈលោកជំទាវ **វង្ស សិរីអមតា** ជាជំនួយការសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អគ្គនាយក**។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៩៧.៤៤៣.៤៦០

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៥៦១

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** និយ័តកម្មដំឡើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដល់លោក **ចិន ខន្តី** ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៥ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ មកជាឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៩៧.៥៤០៣.៥៦១

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានធ្វើសេចក្តីថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/២៦២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងឯកឧត្តម **ជា មូរ៉ា** ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ករស. ២៤០៣.២៦២

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៦៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ឡូន ចែម** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ **រដ្ឋមន្ត្រី**។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរក.២៤០៣.៤៦៣

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៦៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន២រូប ៖

១-វរសេនីយ៍ឯក **ចាន់ សុភាព** អត្តលេខ ៦៧៧៨៨

២-វរសេនីយ៍ឯក **នួន សុខភាព** អត្តលេខ ៨២៩៨៨

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្ស៊ី វិស្សុត**

តសល. ៤៤០៣.៤៦៤

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **ជាតូបការ**

ចំពោះ

ឯកឧត្តម **ហាប់ អូម៉ាលី**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៤
**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ការល.៤៤៣.៤៦៥

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/២៦៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ៤អង្គ/រូប ៖

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**
ព្រះគ្រូវិសុទ្ធិបញ្ញាញាណ ភិក្ខុវីរិយបណ្ឌិតោ **ឡឿន ម៉ាច់**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**
១-លោក **ម៉ា សាវី**
២-លោក **ម៉ាន ចាន់ថា**
៣-លោក **ហែម សុធន**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៤
**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ព្រស.២៤០៣.២៦៦

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា និងថ្នាក់ដឹកនាំ បុគ្គលិក ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ៧រូបៈ

ក-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- H.E Mr. Won Sam CHANG
២- H.E Mr. Jung-Wook PARK

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- Mrs. Moon jung CHOI
២- Ms. Jung Won CHE
៣-Mr. Wangi AHN
៤-Prof. Dae Hwan BAE
៥-Mr. Ouk Rithipol

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៤
**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរល.៤៤០៣.៤៦៧

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

វង្សី វិស្សុត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥៥ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .–**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២៤ | ឥណទានមុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មីក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | **ការផ្ទេរចេញ** | | | | **10.966.500** | |
| | **៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា និងចំណាយមិនបានគ្រោងទុក** | | | | **10.966.500** | |
| 69 | ចំណាយមិនបានគ្រោងទុក | 2.454.267.000 | 2.395.226.100 | - | 10.966.500 | 2.384.259.600 |
| | **ការផ្ទេរចូល** | | | **10.966.500** | | |
| | **០៥.១-ទីស្តីការគណៈរដ្ឋមន្ត្រី** | | | **1.102.200** | | |
| 65 | ឧបត្ថម្ភធន (គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ) | 192.326.000 | 196.569.000 | 1.102.200 | - | 197.671.200 |
| | **១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | | **7.965.000** | | |
| 62 | អត្ថប្រយោជន៍សង្គម | 213.300 | 213.300 | 7.965.000 | - | 8.178.300 |
| | **៣២-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | **1.899.300** | | |
| 62 | អត្ថប្រយោជន៍សង្គម | 154.714.800 | 154.714.800 | 1.899.300 | - | 156.614.100 |

**មាត្រា២ .–**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

១)- ផ្តល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៃទីស្តីការគណៈរដ្ឋមន្ត្រីចំនួន **១ ១០២,២** លានរៀល សម្រាប់ទិញឧបករណ៍សម្ភារពន្លត់អគ្គិភ័យ (PPE) ចំនួន ១១ មុខ។

២)- ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន **៧ ៩៦៥ លានរៀល** សម្រាប់ទូទាត់ប្រាក់កក់ចំនួន ៣០% នៃថ្លៃកិច្ចសន្យាក្នុងបរិមាណអង្ករសរុបចំនួន ១០ ០០០ តោន បម្រុងសម្រាប់ប្រព័ន្ធស្បៀងបម្រុងកម្ពុជា។

៣)-ផ្តល់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន **១ ៨៩៩,៣ លានរៀល** សម្រាប់ទូទាត់ចំណាយរៀបចំកម្មវិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ **ស្ពានសម្តេចតេជោ ហ៊ុន សែន កោះឃ៉ី** ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០២៤។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៥២ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារការកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

## ជំពូកទី២

## មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានមុខងារនិងភារកិច្ចដូចតទៅ៖

- រៀបចំនិងអនុវត្តគោលនយោបាយជាតិស្តីពីវិស័យអាកាសចរណ៍ស៊ីវិល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍអាកាសចរណ៍ស៊ីវិល និងរៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីអភិវឌ្ឍវិស័យអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំ តាក់តែង និងចងក្រងច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិបច្ចេកទេស និងឯកសារណែនាំអនុវត្តផ្សេងៗដែលពាក់ព័ន្ធដល់ការគ្រប់គ្រងវិស័យអាកាសចរណ៍ស៊ីវិល ស្របតាមលក្ខខណ្ឌតម្រូវជាតិនិងអន្តរជាតិ
- រៀបចំសិក្សាវាយតម្លៃ ចរចា តាក់តែង និងស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលលើអនុសញ្ញា សន្ធិសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិល
- គ្រប់គ្រងអាកាសយានដ្ឋានស៊ីវិលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងការប្រើប្រាស់ដែនអាកាស កំណត់តំបន់ហាមឃាត់ តំបន់គ្រោះថ្នាក់ និងតំបន់កម្រិតការហោះហើរ
- គ្រប់គ្រងប្រព័ន្ធអេឡិចត្រូនិកដែលបម្រើឱ្យសេវាកម្មចរាចរដែនអាកាស និងសិក្សាពីតម្រូវការរបស់ប្រព័ន្ធ
- គ្រប់គ្រងលើការផ្តល់សេវាកម្មនាំផ្លូវអាកាស ទូរគមនាគមន៍អាកាសចរណ៍ ឧតុនិយមអាកាសចរណ៍ ការបណ្តុះបណ្តាល និងសេវាកម្មផ្សេងៗទៀត ដែលជាសមត្ថកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- ពិនិត្យនិងផ្តល់វិញ្ញាបនបត្រអាកាសយានដ្ឋានដល់ប្រតិបត្តិករអាកាសយានដ្ឋាន វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសដល់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស លិខិតយល់ព្រមទទួលស្គាល់ដល់អង្គភាពបណ្តុះបណ្តាលអាកាសចរណ៍និងអង្គភាពថែទាំអាកាសយាន
- ត្រួតពិនិត្យនិងតាមដានប្រតិបត្តិការនិងអនុលោមភាពរបស់ប្រតិបត្តិករអាកាសយានដ្ឋាន ប្រតិបត្តិករអាកាសយាន អង្គភាពផ្តល់សេវាកម្មនាំផ្លូវអាកាស អង្គភាពបណ្តុះបណ្តាលអាកាសចរណ៍ និងអង្គភាពថែទាំអាកាសយាន
- ពិនិត្យនិងផ្តល់អាជ្ញាបណ្ណដល់ក្រុមអាកាសយានិក វិស្វករថែទាំអាកាសយាន អ្នកបច្ចេកទេសរោងជាង អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស និងបុគ្គលិកអាកាសចរណ៍ផ្សេងទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- គ្រប់គ្រងការចុះបញ្ជីអាកាសយានស៊ីវិលគ្រប់ប្រភេទ
- គ្រប់គ្រងការចុះបញ្ជី ការអនុញ្ញាតប្រតិបត្តិការហោះហើរដល់អាកាសយានស៊ីវិលគ្មានមនុស្សបើក (ដ្រូន) ព្រមទាំងគ្រប់គ្រងរាល់សកម្មភាពហោះហើរនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តដោយឡែក
- ធានាសន្តិសុខនិងសុវត្ថិភាពហោះហើរដល់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសជាតិនិងអន្តរជាតិ ដែលធ្វើសេវាកម្មនៅក្នុង ចេញ ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- ធានានិងជំរុញឱ្យមាននិរន្តរភាព ប្រសិទ្ធភាព និងគុណភាពសេវាកម្មរបស់បណ្តាសហគ្រាសដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវអាកាស
- គ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអាកាសចរណ៍ស៊ីវិល ឱ្យស្របតាមតម្រូវការនិងស្តង់ដារបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- រៀបចំគោលនយោបាយបណ្តុះបណ្តាល កម្មវិធីបណ្តុះបណ្តាល និងផែនការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យអាកាសចរណ៍ស៊ីវិល ឱ្យស្របតាមតម្រូវការជាតិនិងអន្តរជាតិ ព្រមទាំងតាមដានការអនុវត្ត
- ចេញអាជ្ញាបណ្ណសម្រាប់ការអភិវឌ្ឍពង្រីកអាកាសយានដ្ឋាននិងការកសាងអាកាសយានដ្ឋានថ្មី បន្ទាប់ពីមានការយល់ព្រមពីរាជរដ្ឋាភិបាល
- គ្រប់គ្រងនិងត្រួតពិនិត្យលើការជួសជុល ថែទាំ កែលម្អ ធ្វើនីតិសម្បទា អភិវឌ្ឍ និងសាងសង់អាកាសយានដ្ឋានដែលទទួលខុសត្រូវដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ព្រមទាំងតាមដានគម្រោងការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិនិងមូលដ្ឋាន
- កំណត់ភូមិសាស្ត្រនិងទីតាំងសម្រាប់ពង្រីកអាកាសយានដ្ឋានដែលមានស្រាប់និងទីតាំងសម្រាប់កសាងអាកាសយានដ្ឋានថ្មី ព្រមទាំងកំណត់ព្រំខណ្ឌដីនិងចុះបញ្ជីបណ្ណកម្មសិទ្ធិដីអាកាសយានដ្ឋាន
- រៀបចំកម្មវិធីជាតិស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិលនិងកម្មវិធីផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសន្តិសុខអាកាសចរណ៍ស៊ីវិល ឱ្យស្របតាមស្តង់ដាជាតិនិងអន្តរជាតិ ព្រមទាំងតាមដានការអនុវត្ត
- រៀបចំកម្មវិធីសុវត្ថិភាពរដ្ឋនិងកម្មវិធីផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល ឱ្យស្របតាមស្តង់ដាជាតិនិងអន្តរជាតិ ព្រមទាំងតាមដានការអនុវត្ត
- ពិនិត្យនិងផ្តល់ការអនុញ្ញាតដល់អង្គភាពឬគ្រឹះស្ថានសិក្សានានា ចំពោះការបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្សព្វផ្សាយនិងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ កម្មវិធីជាតិស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល និងកម្មវិធីសុវត្ថិភាពអាកាសចរណ៍ស៊ីវិល
- ទទួលខុសត្រូវក្នុងការរុករក សង្គ្រោះ និងស៊ើបអង្កេតឧប្បត្តិហេតុឬគ្រោះថ្នាក់អាកាសចរណ៍
- អនុវត្តនីតិវិធី វិធានការកែតម្រូវ និងដាក់ទណ្ឌកម្មលើសកម្មភាពបំពានច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល ទាំងកម្រិតជាតិនិងអន្តរជាតិ
- រៀបចំផែនការថវិកាប្រចាំឆ្នាំ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- អនុវត្តគោលនយោបាយថវិកាកម្មវិធី ស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- អនុវត្តនីតិវិធីដេញថ្លៃលទ្ធកម្មសាធារណៈ ស្របតាមគោលការណ៍និងនីតិវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយការងារបច្ចេកទេសពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពរបស់ខ្លួនតាមកាលកំណត់ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៣ ..**

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានរចនាសម្ព័ន្ធដូចតទៅ៖

១- ខុទ្ទកាល័យរដ្ឋមន្ត្រី។

២- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

៣- អគ្គនាយកដ្ឋានបច្ចេកទេស។

៤- អគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស។

៥- អគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្ម។

៦- វិទ្យាស្ថានជាតិអាកាសចរណ៍ស៊ីវិល មានថ្នាក់ស្មើអគ្គនាយកដ្ឋាន។

៧- នាយកដ្ឋាននីតិកម្ម។

៨- នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

៩- អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ មានថ្នាក់ស្មើនាយកដ្ឋាន។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ ..**

អគ្គនាយកដ្ឋានត្រូវដឹកនាំដោយអគ្គនាយក១(មួយ)រូប និងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថានត្រូវដឹកនាំដោយនាយក១(មួយ)រូប មានឋានៈស្មើអគ្គនាយក និងមាននាយករងមួយចំនួនតាមការចាំបាច់ មានឋានៈស្មើអគ្គនាយករង ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកដ្ឋានត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាកាសយានដ្ឋានអន្តរជាតិត្រូវដឹកនាំដោយនាយក១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមាននាយករងមួយចំនួនតាមការចាំបាច់ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ ..**

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននិងអង្គភាពនានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៦ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ទទួលបន្ទុកបេសកកម្មទាំងឡាយដែលបានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន និងអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា៧ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលលើកិច្ចការរដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស ហិរញ្ញវត្ថុ និងបរិវត្តកម្មឌីជីថល និងអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៨ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធដូចតទៅ៖

១- នាយកដ្ឋានរដ្ឋបាល។

២- នាយកដ្ឋានគ្រប់គ្រងធនធានមនុស្ស។

៣- នាយកដ្ឋានហិរញ្ញវត្ថុ។

៤- នាយកដ្ឋានបរិវត្តកម្មឌីជីថល។

**មាត្រា៩ .-**

នាយកដ្ឋានរដ្ឋបាល មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងកិច្ចការរដ្ឋបាល អនុលោមតាមច្បាប់និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់រដ្ឋលេខាធិការដ្ឋាននៅថ្នាក់កណ្តាលនិងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមឱវាទ ពាក់ព័ន្ធនឹងរដ្ឋបាលកិច្ច
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់រដ្ឋលេខាធិការដ្ឋាន
- ទទួលបដិសណ្ឋារកិច្ចភ្ញៀវជាតិនិងអន្តរជាតិរបស់រដ្ឋលេខាធិការដ្ឋាន
- រៀបចំតុបតែងលម្អក្នុងពិធីផ្សេងៗ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- គ្រប់គ្រងបណ្ណសាររបស់រដ្ឋលេខាធិការដ្ឋាន
- រៀបចំនិងគ្រប់គ្រងសណ្តាប់ធ្នាប់ សន្តិសុខ របៀបរៀបរយ និងអនាម័យក្នុងបរិវេណនិងអគាររដ្ឋបាលរបស់រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងសាលប្រជុំរបស់រដ្ឋលេខាធិការដ្ឋាន

- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងការប្រើប្រាស់ថាមពលអគ្គិសនីនិងទឹក ព្រមទាំងថែរក្សានិងប្រើប្រាស់ម៉ាស៊ីនភ្លើងរបស់រដ្ឋលេខាធិការដ្ឋាន
- សហការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងទិសដៅអនុវត្តការងារឆ្នាំបន្តបន្ទាប់របស់រដ្ឋលេខាធិការដ្ឋាន
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរបស់នាយកដ្ឋាន
- ពិនិត្យនិងផ្តល់យោបល់លើការងារទាក់ទងនឹងកិច្ចការគ្រប់គ្រងរដ្ឋបាល និងសុំការសម្រេចពីថ្នាក់ដឹកនាំ
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១០ .-**

នាយកដ្ឋានគ្រប់គ្រងធនធានមនុស្ស មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងកិច្ចការគ្រប់គ្រងធនធានមនុស្ស អនុលោមតាមច្បាប់និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់រដ្ឋលេខាធិការដ្ឋាននៅថ្នាក់កណ្តាលនិងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមឱវាទ ពាក់ព័ន្ធនឹងការងារគ្រប់គ្រងធនធានមនុស្ស
- រៀបចំផែនការជ្រើសរើសមន្ត្រីថ្មីប្រចាំឆ្នាំសម្រាប់រដ្ឋលេខាធិការដ្ឋាន ផ្អែកតាមគោលការណ៍ដែលណែនាំដោយរាជរដ្ឋាភិបាល ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- សហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំនិងអនុវត្តនីតិវិធីជ្រើសរើសមន្ត្រីក្របខ័ណ្ឌរដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់រដ្ឋលេខាធិការដ្ឋាន ដោយធ្វើទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈនិងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃធនធានមនុស្សសម្រាប់ការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មដល់មន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋាន
- សិក្សា ស្រាវជ្រាវ រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍមូលធនមនុស្សនិងស្ថាប័ន
- រៀបចំរាល់លិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងមន្ត្រីជំនាញអាកាសចរណ៍ស៊ីវិល ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំតារាងនិងបើកផ្តល់ប្រាក់បៀវត្ស កាំប្រាក់ និងតារាងប្រាក់កម្រៃផ្សេងៗទៀតជូនមន្ត្រីរាជការក្រោមឱវាទ
- រៀបចំផែនការនិងអនុវត្តការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យអាកាសចរណ៍ស៊ីវិលនិងវិស័យពាក់ព័ន្ធផ្សេងៗទៀត

- គ្រប់គ្រងទិន្នន័យបណ្តុះបណ្តាលរបស់មន្ត្រីអធិការកិច្ច មន្ត្រីបច្ចេកទេស និងមន្ត្រីផ្នែកគាំទ្ររបស់រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងនិងចរាចរឯកសារផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន
- រៀបចំចេញលិខិតអញ្ជើញ រៀបចំពិធីការ និងកិច្ចប្រជុំផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន
- រៀបចំបែបបទបំពេញបេសកកម្មក្នុងប្រទេសរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋាន
- រៀបចំនិងកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធរបស់រដ្ឋលេខាធិការដ្ឋាន ដោយសហការជាមួយនាយកដ្ឋាននីតិកម្មនិងនាយកដ្ឋានអង្គភាពពាក់ព័ន្ធ
- រៀបចំតួនាទីនិងតំណែងឯកទេសរបស់មន្ត្រីជំនាញ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី លើការងារគ្រប់គ្រងធនធានមនុស្ស
- ពិនិត្យនិងផ្តល់យោបល់លើការងារដែលទាក់ទងនឹងការគ្រប់គ្រងធនធានមនុស្ស និងសុំការសម្រេចពីថ្នាក់ដឹកនាំ
- ត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងទិន្នន័យនិងតារាងព័ត៌មានមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋាន
- សហការជាមួយវិទ្យាស្ថានជាតិអាកាសចរណ៍ស៊ីវិល ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសនិងវគ្គបណ្តុះបណ្តាលជំនាញសម្រាប់មន្ត្រីរាជការ
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១១ .-**

នាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុ អនុលោមតាមច្បាប់និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំ សម្របសម្រួល បូកសរុប និងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា
- ប្រមូលផ្តុំ សម្របសម្រួល បូកសរុប និងលើកគម្រោងថវិកាប្រចាំឆ្នាំ
- រៀបចំកម្មវិធីចំណូល ចំណាយសាច់ប្រាក់ប្រចាំត្រីមាស
- គាំទ្រនិងសម្របសម្រួលជាមួយអង្គភាពថវិកាក្នុងការគ្រប់គ្រងថវិកា
- ទទួលខុសត្រូវលើកិច្ចប្រតិបត្តិការចំណូល ចំណាយប្រចាំឆ្នាំ និងកិច្ចបញ្ជិកាគណនេយ្យ
- រៀបចំបង្វែរសាច់ប្រាក់ទាក់ទងនឹងបៀវត្សនិងប្រាក់កម្រៃផ្សេងៗជូនមន្ត្រីរាជការ ទៅនាយកដ្ឋានគ្រប់គ្រងធនធានមនុស្ស
- រៀបចំ គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្ម
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិគ្រប់កម្រិត
- រៀបចំគម្រោងនិងកម្មវិធីសាងសង់ ជួសជុល ថែទាំសំណង់ អគារ និងសម្ភារៈបរិក្ខារគ្រប់ប្រភេទ រៀបចំចុះកិច្ចបញ្ជិកាជាប្រចាំ
- កត់ត្រា តាមដាន និងបូកសរុបប្រតិបត្តិការថវិកាចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលការងារសម្រេចបាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- គ្រប់គ្រងយានដ្ឋាន យានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទរបស់រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងនិងបែងចែកសម្ភារៈបរិក្ខារនិងប្រេងឥន្ធនៈដល់បណ្តាអង្គភាពក្រោមឱវាទរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្ម
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១២ .-**

នាយកដ្ឋានបរិវត្តកម្មឌីជីថល មានភារកិច្ចដូចតទៅៈ

- រៀបចំនិងចងក្រងផែនការអភិវឌ្ឍការងារបច្ចេកវិទ្យាឌីជីថលនីយកម្ម បទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តលើវិស័យអាកាសចរណ៍ស៊ីវិល អនុលោមទៅតាមច្បាប់ និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំផែនការសកម្មភាពនិងកម្មវិធីការងារ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន
- អនុវត្តតាមការណែនាំនិងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លើការងារពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- រៀបចំបង្កើតនិងពង្រឹងយន្តការយុទ្ធសាស្ត្រនិងគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីទ្រទ្រង់ការអភិវឌ្ឍវិស័យអាកាសចរណ៍ឱ្យកាន់តែមានប្រសិទ្ធភាព
- គ្រប់គ្រងការងារទូទៅពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍សម្រាប់វិស័យអាកាសចរណ៍
- រៀបចំ គ្រប់គ្រង តភ្ជាប់បណ្តាញ ជួសជុល ថែរក្សាម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ព័ត៌មានវិទ្យា និងកម្មវិធីកុំព្យូទ័ររបស់រដ្ឋលេខាធិការដ្ឋាន សំដៅធានាប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យចាំបាច់ក្នុងការលើកកម្ពស់វិស័យអាកាសចរណ៍
- រៀបចំបង្កើតនិងគ្រប់គ្រងគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងបណ្តាញទូរគមនាគមន៍ បណ្តាញទូរសារ និងទូរសព្ទក្នុងរដ្ឋលេខាធិការដ្ឋាន
- សហការជាមួយអង្គភាពទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិ ធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិលើការងារពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សម្រាប់រដ្ឋលេខាធិការដ្ឋាននិងវិស័យអាកាសចរណ៍ទាំងមូល
- បណ្តុះបណ្តាលនិងផ្សព្វផ្សាយការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា កម្មវិធីកុំព្យូទ័រដល់មន្ត្រីរដ្ឋលេខាធិការដ្ឋាននិងមន្ត្រីនៃវិស័យអាកាសចរណ៍
- ប្រមូលផ្តុំនិងចងក្រងឯកសារការងារផ្សេងៗ សម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំ ចងក្រង និងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់រដ្ឋលេខាធិការដ្ឋាន និងចូលរួមកំណត់កម្មវិធីអភិវឌ្ឍន៍
- បង្កើតប្រព័ន្ធសុវត្ថិភាពនិងថែរក្សាឯកសារប្រកបដោយសុវត្ថិភាពសម្រាប់រដ្ឋលេខាធិការដ្ឋាន

- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារព័ត៌មានវិទ្យានិងបរិវត្តកម្មឌីជីថល
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អគ្គនាយកដ្ឋានបច្ចេកទេស

**មាត្រា១៣ .-**

អគ្គនាយកដ្ឋានបច្ចេកទេស មានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលលើកិច្ចការស្តង់ដាប្រតិបត្តិការហោះហើរ លទ្ធភាពហោះហើរ ស្តង់ដានាំផ្លូវអាកាស ស្តង់ដាអាកាសយានដ្ឋាន សន្តិសុខអាកាសចរណ៍ស៊ីវិល ការធានាគុណភាពស្តង់ដាសុវត្ថិភាព អាជ្ញាបណ្ណបុគ្គលិក និងទំនាក់ទំនងអន្តរជាតិ និងអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា១៤ .-**

អគ្គនាយកដ្ឋានបច្ចេកទេស មានរចនាសម្ព័ន្ធដូចតទៅៈ

១- នាយកដ្ឋានស្តង់ដាប្រតិបត្តិការហោះហើរ។
២- នាយកដ្ឋានលទ្ធភាពហោះហើរ។
៣- នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពនាំផ្លូវអាកាស។
៤- នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន។
៥- នាយកដ្ឋានសន្តិសុខអាកាសចរណ៍ស៊ីវិល។
៦- នាយកដ្ឋានធានាគុណភាពស្តង់ដាសុវត្ថិភាព។
៧- នាយកដ្ឋានអាជ្ញាបណ្ណបុគ្គលិក។
៨- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ។

**មាត្រា១៥ .-**

នាយកដ្ឋានស្តង់ដាប្រតិបត្តិការហោះហើរ មានភារកិច្ចដូចតទៅៈ

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងស្តង់ដាប្រតិបត្តិការហោះហើរ អនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- ពិនិត្យនិងវាយតម្លៃបច្ចេកទេស ក្នុងការផ្តល់ ផ្អាក ដកហូត បដិសេធ ឬបន្តវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត ឬបន្តលិខិតអនុញ្ញាតប្រតិបត្តិការ ហោះហើរនៃអាកាសយានគ្រប់ប្រភេទរបស់ប្រតិបត្តិករបរទេស មុនអនុញ្ញាតចាត់តាំងហោះហើរចេញ ចូល និងនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ពិនិត្យនិងវាយតម្លៃបច្ចេកទេស ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការផ្តល់ ផ្អាក ឬបដិសេធលើការស្នើសុំសិទ្ធិប្រតិបត្តិការពិសេស រួមមានប្រតិបត្តិការហោះហើរបង្វែរទិសដែលអាចពន្យារពេលហោះហើរបាន ការនាំផ្លូវហោះហើរផ្អែកលើប្រព័ន្ធផ្កាយរណប ប្រតិបត្តិការនាំផ្លូវតាមស្តង់ដាកំណត់ ការនាំផ្លូវអាកាសតាមតំបន់ ប្រតិបត្តិការគ្រប់ស្ថានភាពអាកាសធាតុ ការកំណត់ប្រតិបត្តិការនាំផ្លូវអាកាសអប្បបរមា ការកាត់បន្ថយគម្លាតកម្ពស់អប្បបរមា ឯកសារហោះហើរជាអេឡិចត្រូនិក
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការយល់ព្រមឱ្យប្រើប្រាស់ម៉ាស៊ីនហោះហើរត្រាប់តាម
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការយល់ព្រមឱ្យប្រើប្រាស់បន្ទប់ហ្វឹកហាត់សម្រាប់ក្រុមហោះគ្រូបង្វឹក នីតិវិធីបង្ការភាពអាសន្ន មធ្យោបាយពិសេសនៃការនាំផ្លូវអាកាស និងកម្មវិធីបង្ការភាពនឿយហត់របស់ក្រុមហោះ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការផ្តល់វិញ្ញាបនបត្រប្រតិបត្តិការអាកាសចរណ៍ទូទៅ(អាកាសយានធុនស្រាលដែលមានទម្ងន់ក្រោម៧៥០០គ.ក្រ.)
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការយល់ព្រមលើកម្មវិធីបណ្តុះបណ្តាលទំនិញគ្រោះថ្នាក់ សៀវភៅណែនាំស្តីពីទំនិញគ្រោះថ្នាក់ គ្រប់អង្គភាពដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការលើកលែងនិងការយល់ព្រមលើការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ដែលបានហាមឃាត់តាមការដឹកជញ្ជូនតាមផ្លូវអាកាស
- ផ្តល់ការយល់ព្រមលើអង្គភាពបណ្តុះបណ្តាលហោះហើរ ដោយសហការជាមួយនាយកដ្ឋានអាជ្ញាបណ្ណបុគ្គលិក
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការផ្តល់សេវាកម្មផ្ទៃដីរវាងប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាស និងអ្នកផ្តល់សេវាកម្មផ្ទៃដី ដោយសហការជាមួយនាយកដ្ឋានលទ្ធភាពហោះហើរ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត បដិសេធ ឬបន្តវិញ្ញាបនបត្រកម្មវិធីហ្វឹកហ្វឺនបុគ្គលិកអាកាសចរណ៍របស់ប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាស
- សហការធ្វើអធិការកិច្ចនិងត្រួតពិនិត្យតាមដានការអនុវត្តលើកិច្ចប្រតិបត្តិការសេវាកម្មផ្ទៃដី
- ត្រួតពិនិត្យតាមដានជាប្រចាំលើសកម្មភាពរបស់ប្រតិបត្តិករដែលកាន់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន
- ត្រួតពិនិត្យតាមដានសកម្មភាពគ្រប់អង្គភាពដែលពាក់ព័ន្ធនឹងសុវត្ថិភាពនៃការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស
- ត្រួតពិនិត្យតាមដានសកម្មភាពរបស់អាកាសយានិកឯកជននិងប្រតិបត្តិករអាកាសយានធុនស្រាលដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ត្រួតពិនិត្យតាមដានប្រតិបត្តិករអាកាសយានបរទេសដែលប្រតិបត្តិការហោះហើរនៅក្នុង ចេញ ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយនាយកដ្ឋានលទ្ធភាពហោះហើរ
- សហការអនុវត្តនិងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពអាកាសចរណ៍និងផែនការសុវត្ថិភាពអាកាសចរណ៍ ដើម្បីឆ្លើយតបទៅនឹងផែនការសុវត្ថិភាពអាកាសចរណ៍សកល
- សហការផ្តល់យោបល់លើការបង្កើតនិងអនុវត្តកម្មវិធីសុវត្ថិភាពរដ្ឋ

- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេសដែលទាក់ទងនឹងស្តង់ដាប្រតិបត្តិការហោះហើរ ដើម្បីសុំការពិនិត្យនិងសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារស្តង់ដាប្រតិបត្តិការហោះហើរ
- ទទួលខុសត្រូវលើការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

**មាត្រា១៦ .-**

នាយកដ្ឋានលទ្ធភាពហោះហើរ មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងការត្រួតពិនិត្យលទ្ធភាពហោះហើរ អនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំនិងចងក្រងសេចក្តីព្រាងបទប្បញ្ញត្តិ ស្តង់ដា និងនីតិវិធីស្តីពីការកំណត់អាយុអាកាសយានដែលប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការផ្តល់យោបល់លើកិច្ចការពារបរិស្ថានពាក់ព័ន្ធនឹងឧបសម្ព័ន្ធទី១៦នៃអនុសញ្ញាស៊ីកាហ្គោ
- សហប្រតិបត្តិការជាមួយអាជ្ញាធរអាកាសចរណ៍ស៊ីវិលនៃប្រទេសដែលផ្តល់វិញ្ញាបនបត្របញ្ជាក់ពីប្រភេទអាកាសយាន និងរោងចក្រផលិតអាកាសយានដែលត្រូវបាននាំចូលលើកដំបូងមកចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ដកពីបញ្ជីនៃការចុះបញ្ជីអាកាសយានស៊ីវិល បដិសេធ ផ្អាក និងដកហូតនូវវិញ្ញាបនបត្រចុះបញ្ជី និងវិញ្ញាបនបត្រសំឡេងអាកាសយាន
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ បដិសេធ ផ្អាក និងដកហូតនូវវិញ្ញាបនបត្រអនុញ្ញាតឱ្យធ្វើប្រតិបត្តិការហោះហើរនៅក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះអាកាសយានចុះបញ្ជីបរទេស
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ បដិសេធ ផ្អាក ដកហូត និងបន្តសុពលភាពវិញ្ញាបនបត្រលទ្ធភាពហោះហើរ អាជ្ញាបណ្ណវិទ្យុអាកាសយាន អាជ្ញាបណ្ណស្ថានីយប្រេងអាកាសយាន និងវិញ្ញាបនបត្រអង្គភាពថែទាំបច្ចេកទេសអាកាសយាន
- ត្រួតពិនិត្យការបន្តលទ្ធភាពហោះហើរចំពោះអាកាសយានដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយនាយកដ្ឋានស្តង់ដាប្រតិបត្តិការហោះហើរ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធដទៃទៀតក្នុងការពិនិត្យនិងវាយតម្លៃបច្ចេកទេស ដើម្បីផ្តល់ បដិសេធ ផ្អាក ដកហូត និងបន្តសុពលភាពវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស លក្ខខណ្ឌប្រតិបត្តិការរបស់អាកាសយានបរទេស និងការទទួលខុសត្រូវផ្សេងទៀតចំពោះអាកាសយានដែលធ្វើប្រតិបត្តិការនៅក្នុងនិងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយនាយកដ្ឋានស្តង់ដាប្រតិបត្តិការហោះហើរ ក្នុងការត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសដើម្បីយល់ព្រមលើបញ្ជីបរិក្ខារអប្បបរមា ប្រតិបត្តិការហោះហើរបង្វែរទិសដែលអាចពន្យារពេលហោះហើរបាន ការនាំផ្លូវហោះហើរផ្អែកលើប្រព័ន្ធផ្កាយរណប ការកាត់បន្ថយគម្លាតកម្ពស់អប្បបរមាប្រតិបត្តិការហោះហើរក្នុងកម្រិតទាប និងឯកសារហោះហើរជាអេឡិចត្រូនិក

- ពិនិត្យនិងវាយតម្លៃបច្ចេកទេស ផ្តល់ការយល់ព្រមលើសៀវភៅណែនាំស្តីពីការគ្រប់គ្រងបច្ចេកទេសថែទាំអាកាសយាន សៀវភៅបទដ្ឋានសម្រាប់ការថែទាំបច្ចេកទេសអាកាសយាន សៀវភៅបទដ្ឋានធានារ៉ាប់រងគុណភាព សៀវភៅណែនាំស្តីពីលក្ខខណ្ឌបំពេញបន្ថែមពិសេសសម្រាប់រោងជាងថែទាំអាកាសយានបរទេស សៀវភៅកម្មវិធីបណ្តុះបណ្តាលបុគ្គលិកថែទាំបច្ចេកទេសអាកាសយាន សៀវភៅកម្មវិធីថែទាំបច្ចេកទេសអាកាសយាន សៀវភៅស្តីពីកម្មវិធីគ្រប់គ្រងនិងតាមដានប្រតិបត្តិការអាកាសយានដែលទុកចិត្តបាន សៀវភៅណែនាំស្តីពីគ្រប់គ្រងសុវត្ថិភាព កិច្ចសន្យាស្តីពីការថែទាំបច្ចេកទេសអាកាសយាន និងកិច្ចព្រមព្រៀងជួលអាកាសយាន
- ធ្វើការត្រួតពិនិត្យតាមដានជាប្រចាំ និងធ្វើសវនកម្មទៅលើប្រតិបត្តិករអាកាសយាននិងអង្គភាពថែទាំបច្ចេកទេសអាកាសយាន
- សហការផ្តល់ព័ត៌មានលើការស៊ើបអង្កេតឧបទ្ទវហេតុឬឧប្បត្តិហេតុអាកាសយាននៅក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការងារត្រួតពិនិត្យលទ្ធភាពហោះហើរ ដើម្បីស្នើសុំការសម្រេចពីថ្នាក់ដឹកនាំ
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

**មាត្រា១៧ .-**

នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពនាំផ្លូវអាកាស មានភារកិច្ចដូចតទៅ៖

- រៀបចំចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងសុវត្ថិភាពនាំផ្លូវអាកាស ដើម្បីត្រួតពិនិត្យទៅលើអ្នកផ្តល់សេវាកម្ម រួមមានសេវាកម្មចរាចរដែនអាកាស សេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍វិទ្យា សេវាកម្មប្រព័ន្ធទាក់ទងផ្ទៃដី អាកាស នាំផ្លូវអាកាស និងឃ្លាំមើលដែនអាកាស សេវាកម្មបទដ្ឋានហោះហើរ សេវាកម្មគូរផែនទីអាកាសចរណ៍ សេវាកម្មផ្តល់ព័ត៌មានឧតុនិយមអាកាសចរណ៍ សេវាកម្មរុករកនិងសង្គ្រោះ និងការគ្រប់គ្រង រលកធាតុអាកាសអាកាសចរណ៍ស៊ីវិល អនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំនិងធ្វើផែនការដើម្បីកំណត់ដែនអាកាស អាកាសវិថី តំបន់ហាមឃាត់ តំបន់គ្រោះថ្នាក់ និងតំបន់ហោះចេញនិងហោះចូលរបស់អាកាសយាន
- រៀបចំចងក្រងនីតិវិធី ឯកសារ និងសៀវភៅណែនាំសម្រាប់ការធ្វើសវនកម្មលើអ្នកផ្តល់សេវាកម្ម
- រៀបចំចងក្រងផែនការនាំផ្លូវអាកាស រួមមានផែនការជាតិ ផែនការតំបន់ និងផែនការសកលដោយសហការជាមួយក្រុមហ៊ុនផ្តល់សេវាកម្មក្នុងប្រទេស ប្រទេសជិតខាង ប្រទេសអាស៊ាន និងអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- ពិនិត្យនិងអនុម័តលើសៀវភៅណែនាំប្រតិបត្តិការរបស់អ្នកផ្តល់សេវាកម្មនាំផ្លូវអាកាស រួមមានសេវាកម្មចរាចរដែនអាកាស សេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍វិទ្យា សេវាកម្មប្រព័ន្ធទាក់ទងផ្ទៃដីអាកាស នាំផ្លូវអាកាស និងឃ្លាំមើលដែនអាកាស សេវាកម្មបទដ្ឋានហោះហើរ សេវាកម្មគូរផែនទីអាកាសចរណ៍ សេវាកម្មផ្តល់ព័ត៌មានឧតុនិយមអាកាសចរណ៍ និងសេវាកម្មរុករកនិងសង្គ្រោះ

- សហការជាមួយនាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន ក្នុងការត្រួតពិនិត្យកម្ពស់ឧបសគ្គ (សំណង់ អគារ អង់តែន ដើមឈើ និងឧបសគ្គដទៃទៀតដែលបង្កើតឡើងដោយមនុស្ស) នៅក្នុងអាកាសយានដ្ឋាននិងតំបន់ជុំវិញអាកាសយានដ្ឋាន ដើម្បីផ្តល់ការអធិការកិច្ចអនុញ្ញាតឱ្យសាងសង់និងប្រតិបត្តិការ
- ត្រួតពិនិត្យ វាយតម្លៃបច្ចេកទេស ចេញវិញ្ញាបនបត្រ និងធ្វើសវនកម្មទៅលើអ្នកផ្តល់សេវាកម្ម រួមមានសេវាកម្មចរាចរដែនអាកាស សេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍វិទ្យា សេវាកម្មប្រព័ន្ធទាក់ទងផ្ទៃដី អាកាស នាំផ្លូវអាកាស និងឃ្លាំមើលដែនអាកាស សេវាកម្មបទដ្ឋានហោះហើរ សេវាកម្មគូរផែនទី សេវាកម្មផ្តល់ព័ត៌មានឧតុនិយមអាកាសចរណ៍ សេវាកម្មរុករកនិងសង្គ្រោះ ដោយកំណត់ចំណុចខ្វះខាតនិងសេចក្តីណែនាំសម្រាប់ដោះស្រាយបញ្ហាដែលបានរកឃើញ
- ត្រួតពិនិត្យនិងអនុម័តលើទិន្នន័យព័ត៌មានអាកាសចរណ៍វិទ្យា បទដ្ឋានហោះហើរ និងផែនទីអាកាសចរណ៍
- ត្រួតពិនិត្យនិងផ្តល់ការអនុញ្ញាតក្នុងការដំឡើងឬដកចេញនូវឧបករណ៍ឬប្រព័ន្ធទាក់ទងនាំផ្លូវ និងឃ្លាំមើលដែនអាកាស និងឧបករណ៍ឬប្រព័ន្ធឧតុនិយមអាកាសចរណ៍
- រៀបចំចាត់ចែងនូវរលកធាតុអាកាសដែលបានអនុញ្ញាតដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងរៀបចំបែងចែករលកធាតុអាកាសសម្រាប់អ្នកផ្តល់សេវាកម្មនិងអ្នកប្រើប្រាស់ផ្សេងៗទៀត
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការត្រួតពិនិត្យគ្រប់គ្រងរលកធាតុអាកាស ដើម្បីជៀសវាងការរំខានដល់សេវាកម្មនាំផ្លូវអាកាស
- ត្រួតពិនិត្យនិងផ្តល់យោបល់លើកិច្ចប្រតិបត្តិការរុករកនិងសង្គ្រោះរបស់អង្គភាពផ្តល់សេវាកម្មរុករកនិងសង្គ្រោះ
- រៀបចំនិងផ្តល់ការអនុញ្ញាតហោះហើរឆ្លងកាត់ដល់ក្រុមហ៊ុនអាកាសចរណ៍ដែលធ្វើការហោះហើរក្នុងដែនអាកាសកម្ពុជា ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- រៀបចំនិងផ្តល់ការអនុញ្ញាតសម្រាប់ការហោះហើរ ចុះចតក្រៅកម្មវិធី ដូចជាការហោះហើរពិសេសសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិនិងអន្តរជាតិ ការហោះហើរឯកជន យោធា មនុស្សធម៌ ពេលមានអាសន្ន សង្គ្រោះបន្ទាន់ ហ្វឹកហាត់ ហោះហើរបញ្ចៀសអាកាសធាតុ ការហោះហើរដើម្បីត្រួតពិនិត្យនិងបញ្ជាក់សមត្ថភាពឧបករណ៍នាំផ្លូវ ផ្លូវហោះ បទដ្ឋានហោះហើរ ការហោះហើរបម្រើឱ្យការថតផែនទីភូមិសាស្ត្រ កសិកម្ម ប៉ូលិស គយ និងការរុករកនិងសង្គ្រោះ។ល។ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- រៀបចំចងក្រងសារាចរណែនាំស្តីពីការគ្រប់គ្រងបែងចែកម៉ោងហោះហើរនិងចុះចតនៅអាកាសយានដ្ឋានសម្រាប់ក្រុមហ៊ុនអាកាសចរណ៍ និងដាក់បញ្ចូលផ្សព្វផ្សាយនៅក្នុងសៀវភៅព័ត៌មានអាកាសចរណ៍វិទ្យា
- រៀបចំនិងផ្តល់ការអនុញ្ញាតប្រតិបត្តិការដល់យន្តហោះធុនស្រាល រួមមានយន្តហោះគ្មានមនុស្សបើកបាឡុង ខ្លែង ជាដើម និងរាល់សកម្មភាពហោះហើរផ្សេងៗទៀតដែលបម្រើឱ្យវិស័យអាកាសចរណ៍ស៊ីវិល
- រៀបចំកិច្ចព្រមព្រៀងផ្នែកប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បណ្តាប្រទេសជិតខាង ឬអ្នកផ្តល់សេវាកម្មផ្សេងៗ រួមមានសេវាកម្មចរាចរដែនអាកាស សេវាកម្មផ្តល់ព័ត៌មាន អាកាស

ចរណ៍វិទ្យា សេវាកម្មប្រព័ន្ធទាក់ទងផ្ទៃដី អាកាស នាំផ្លូវអាកាស និងឃ្លាំមើលដែនអាកាស សេវាកម្មបទដ្ឋានហោះហើរ សេវាកម្មគូរផែនទីអាកាសចរណ៍ សេវាកម្មផ្តល់ព័ត៌មានឧតុនិយមអាកាសចរណ៍ និងសេវាកម្ម រុករកនិងសង្គ្រោះ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ

- ធ្វើការត្រួតពិនិត្យតាមដានជាប្រចាំ និងធ្វើសវនកម្មទៅលើអ្នកផ្តល់សេវាកម្ម រួមមានសេវាកម្មចរាចរដែនអាកាស សេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍វិទ្យា សេវាកម្មប្រព័ន្ធទាក់ទង ផ្ទៃដី អាកាស នាំផ្លូវអាកាស និងឃ្លាំមើលដែនអាកាស សេវាកម្មបទដ្ឋានហោះហើរ សេវកម្មគូរផែនទីអាកាសចរណ៍ សេវាកម្មផ្តល់ព័ត៌មានឧតុនិយមអាកាសចរណ៍ និងសេវាកម្មរុករកនិងសង្គ្រោះ
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេសដែលទាក់ទងនឹងស្តង់ដានិងសុវត្ថិភាពនាំផ្លូវអាកាស ដើម្បីសុំការពិនិត្យនិងសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារស្តង់ដានិងសុវត្ថិភាពនាំផ្លូវអាកាស
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

**មាត្រា១៨ .-**

នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវការ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពរបស់ប្រតិបត្តិករអាកាសយានដ្ឋាន ផែនការគ្រោះអាសន្នអាកាសយានដ្ឋាន លំហាត់សមយុទ្ធទ្រង់ទ្រាយធំ កិច្ចការសង្គ្រោះនិងពន្លត់អគ្គិភ័យ កិច្ចការពារបរិស្ថាន បង្ការផលប៉ះពាល់នៃសត្វបង្កគ្រោះថ្នាក់ ការកំណត់កម្ពស់ឧបសគ្គ ការកំណត់តំបន់ប្រើប្រាស់ភ្លើងបញ្ចាំង ប៉ះពាល់សុវត្ថិភាពអាកាសចរណ៍ និងការរៀបចំប្រព័ន្ធនិងផ្គត់ផ្គង់ទឹកភ្លើង អនុលោមតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- បង្កើតកម្មវិធីនិងត្រួតពិនិត្យការអនុវត្តស្តង់ដាសម្រាប់គម្រោងកសាងអាកាសយានដ្ឋានដែលមានស្រាប់និងអាកាសយានដ្ឋានថ្មី សិក្សាទីតាំង កិច្ចដំណើរការ(រួមទាំងសម្ភារៈនិងបរិក្ខារ) ការងារវិស្វកម្ម និងជួសជុលថែទាំ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើរបាយការណ៍ការបំភាយឧស្ម័នកាបូនិករបស់ប្រតិបត្តិករអាកាសយាន និងបញ្ជូនទៅអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើរបាយការណ៍ផលប៉ះពាល់នៃសត្វបង្កគ្រោះថ្នាក់ និងបញ្ជូនទៅអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- ពិនិត្យនិងទទួលស្គាល់លើសៀវភៅណែនាំប្រតិបត្តិការរបស់ប្រតិបត្តិករអាកាសយានដ្ឋាន
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើផែនការគ្រោះអាសន្នអាកាសយានដ្ឋាន
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើសំណើសុំផ្តល់ បដិសេធ ផ្អាក និងដកហូតអាជ្ញាបណ្ណសម្រាប់សាងសង់អាកាសយានដ្ឋានថ្មី

- ពិនិត្យនិងវាយតម្លៃបច្ចេកទេស និងធ្វើសវនកម្មក្នុងការផ្តល់ បដិសេធ ផ្អាក និងដកហូតវិញ្ញាបនបត្រអាកាសយានដ្ឋាន វិញ្ញាបនបត្រសេវាកម្មលើផ្ទៃដី និងសេវាកម្មពាក់ព័ន្ធនឹងអាកាសយានដ្ឋានដទៃទៀត
- ពិនិត្យនិងតាមដានការអនុវត្តវិធានការសុវត្ថិភាព ដើម្បីទប់ស្កាត់រាល់សកម្មភាពទាំងឡាយណាដែលប៉ះពាល់ដល់សុវត្ថិភាពហោះហើរនិងអាកាសយានដ្ឋាន
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសស្តីពីឧបសគ្គទាំងឡាយណាដែលរំខានទាំងនៅក្នុងនិងជុំវិញអាកាសយានដ្ឋាននិងការអនុវត្ត ឱ្យបានសមស្របតាមស្តង់ដានិងការណែនាំ ដូចមានចែងអំពីសញ្ញានិងភ្លើងរំខាន
- ត្រួតពិនិត្យតាមដានជាប្រចាំ និងធ្វើសវនកម្មទៅលើប្រតិបត្តិករអាកាសយានដ្ឋាន សេវាកម្មលើផ្ទៃដីនិងសេវាកម្មពាក់ព័ន្ធនឹងអាកាសយានដ្ឋានដទៃទៀត
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើការងារទាក់ទងនឹងស្តង់ដាសុវត្ថិភាពអាកាសយានដ្ឋាន និងសុំការសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

**មាត្រា១៩ .-**

នាយកដ្ឋានសន្តិសុខអាកាសចរណ៍ស៊ីវិល មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ កម្មវិធីសន្តិសុខ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងសន្តិសុខអាកាសចរណ៍ស៊ីវិល អនុលោមតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំបង្កើតនិងធ្វើទំនើបកម្មកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរណ៍ស៊ីវិល កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរណ៍ស៊ីវិល និងកម្មវិធីជាតិសម្របសម្រួលការដឹកជញ្ជូនតាមផ្លូវអាកាស
- រៀបចំផែនការនិងកម្មវិធីហ្វឹកហ្វឺនសម្រាប់បណ្តុះបណ្តាលនិងហ្វឹកហ្វឺនដល់មន្ត្រី បុគ្គលិកសន្តិសុខនៃអង្គភាពនិងស្ថាប័នពាក់ព័ន្ធ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើកម្មវិធីសន្តិសុខរបស់ប្រតិបត្តិករអាកាសយាន ប្រតិបត្តិករអាកាសយានដ្ឋាន ប្រតិបត្តិករនាំផ្លូវអាកាស និងប្រតិបត្តិករនានា ដើម្បីស្នើសុំការពិនិត្យសម្រេចពីថ្នាក់ដឹកនាំ
- ត្រួតពិនិត្យនិងវាយតម្លៃគុណភាពសន្តិសុខអាកាសចរណ៍ស៊ីវិល តាមរយៈការធ្វើសវនកម្ម អធិការកិច្ច ការអង្កេត ការធ្វើតេស្ត និងការស៊ើបអង្កេត ដើម្បីធានាថាវិធានការសន្តិសុខអាកាសចរណ៍ស៊ីវិលត្រូវបានអនុវត្តស្របតាមកម្មវិធីជាតិពាក់ព័ន្ធនឹងសន្តិសុខអាកាសចរណ៍ស៊ីវិលដែលបានអនុម័ត
- ពិនិត្យនិងរៀបចំផែនការការពារ ធានាសន្តិសុខនិងសុវត្ថិភាព ដោយសហការជាមួយនាយកដ្ឋានដទៃទៀត និងជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការទប់ស្កាត់នូវរាល់អំពើរំលោភបំពាន បំផ្លិចបំផ្លាញដោយខុសច្បាប់ដល់វិស័យអាកាសចរណ៍ស៊ីវិល

- ចូលរួមសហការលើការត្រួតពិនិត្យផែនការអាសន្នអាកាសយានដ្ឋាន និងការរៀបចំការធ្វើលំហាត់សមយុទ្ធគ្រាអាសន្នទ្រង់ទ្រាយធំ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសលើផែនការគ្រោះអាសន្នសន្តិសុខ
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងសន្តិសុខអាកាសចរណ៍ស៊ីវិល និងសុំការសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារសន្តិសុខអាកាសចរណ៍ស៊ីវិល
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

**មាត្រា២០ .-**

នាយកដ្ឋានធានាគុណភាពស្តង់ដាសុវត្ថិភាព មានភារកិច្ចដូចតទៅ៖

- រៀបចំចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវកម្មវិធីសៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល អនុលោមទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំនិងគ្រប់គ្រងកម្មវិធីសុវត្ថិភាពរដ្ឋ និងសម្របសម្រួលការគ្រប់គ្រងផែនការសុវត្ថិភាពអាកាសចរណ៍សកល និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- សម្របសម្រួលនិងធានាការអនុវត្តការងារដែលទាក់ទងដល់ការពង្រឹងធានាគុណភាពសុវត្ថិភាពអាកាសចរណ៍
- ពិនិត្យនិងផ្តល់យោបល់លើការគ្រប់គ្រងប្រព័ន្ធធានាគុណភាពអាកាសចរណ៍ រៀបចំឱ្យមានស្តង់ដាគុណភាពអាកាសចរណ៍ និងត្រួតពិនិត្យតាមដានគុណភាពអាកាសចរណ៍ តាមរយៈការត្រួតពិនិត្យគុណភាពសុវត្ថិភាពតាមនាយកដ្ឋាននិងអង្គភាពជំនាញ
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេសដែលទាក់ទងដល់ស្តង់ដាសុវត្ថិភាពអាកាសចរណ៍ស៊ីវិល និងសុំការសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងចុះត្រួតពិនិត្យគុណភាពសុវត្ថិភាពអាកាសចរណ៍ស៊ីវិលតាមនាយកដ្ឋាននិងអង្គភាពជំនាញនៃរដ្ឋលេខាធិការដ្ឋាន
- ដឹកនាំការសិក្សាស្រាវជ្រាវទាក់ទងនឹងសុវត្ថិភាពអាកាសចរណ៍ និងរាយការណ៍ពីលទ្ធផលជូនថ្នាក់ដឹកនាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាទាក់ទងនឹងការងារសុវត្ថិភាពនិងធានាគុណភាពអាកាសចរណ៍
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារធានាគុណភាពស្តង់ដាសុវត្ថិភាពអាកាសចរណ៍
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

**មាត្រា២១ .-**

នាយកដ្ឋានអាជ្ញាបណ្ណបុគ្គលិក មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណបុគ្គលិកនិងការកំណត់កម្រិតជំនាញ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- ពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ បដិសេធ ផ្អាក ដកហូត បញ្ជាក់ទទួលស្គាល់ ប្តូរទម្រង់ ផ្តល់ឡើងវិញ និងបន្តសុពលភាពវិញ្ញាបនបត្រ អាជ្ញាបណ្ណឬកម្រិតជំនាញដល់ក្រុមអាកាសយានិក វិស្វករថែរក្សាបច្ចេកទេសអាកាសយាន បុគ្គលិកបញ្ជាចរាចរផ្លូវអាកាស បុគ្គលិកប្រតិបត្តិការហោះហើរ និងអ្នកជំនាញពាក់ព័ន្ធដទៃទៀត
- ពិនិត្យនិងរៀបចំប្រឡងទ្រឹស្តីនិងសមត្ថភាពបច្ចេកទេស ដើម្បីផ្តល់ឬបន្តសុពលភាពវិញ្ញាបនបត្រ ការប្តូរទម្រង់អាជ្ញាបណ្ណ និងការផ្តល់អាជ្ញាបណ្ណឡើងវិញសម្រាប់ក្រុមអាកាសយានិក វិស្វករថែទាំបច្ចេកទេសអាកាសយាន បុគ្គលិកបញ្ជាចរាចរផ្លូវអាកាស បុគ្គលិកប្រតិបត្តិការហោះហើរ និងអ្នកជំនាញពាក់ព័ន្ធដទៃទៀត
- ពិនិត្យនិងរៀបចំការប្រឡង និងវាយតម្លៃកម្រិតសមត្ថភាពភាសាអង់គ្លេសក្នុងវិស័យអាកាសចរណ៍ស៊ីវិល ដើម្បីផ្តល់ឬបន្តសុពលភាពសម្រាប់ក្រុមអាកាសយានិក បុគ្គលិកបញ្ជាចរាចរផ្លូវអាកាស
- សហការផ្សព្វផ្សាយបទប្បញ្ញត្តិ បទបញ្ជាអាកាសចរណ៍ស៊ីវិល លក្ខខណ្ឌតម្រូវលទ្ធភាពហោះហើរស៊ីវិល ស្តង់ដាអាជ្ញាបណ្ណនិងកម្រិតជំនាញ ដែលបានផ្តល់ការយល់ព្រមនិងធ្វើវិសោធនកម្មជាបន្តបន្ទាប់ និងធានាថារាល់ឯកសារណែនាំទាំងអស់ត្រូវបានបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រព័ត៌មានអាកាសចរណ៍
- ធានាថារាល់សកម្មភាពផ្តល់អាជ្ញាបណ្ណនិងកម្រិតជំនាញ ត្រូវបានសម្របសម្រួលជាមួយនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ
- ពិនិត្យនិងវាយតម្លៃបច្ចេកទេស ក្នុងការផ្តល់និងការផ្លាស់ប្តូរអាជ្ញាបណ្ណបុគ្គលិកនិងកម្រិតជំនាញ និងការយល់ព្រមទទួលស្គាល់អង្គភាពបណ្តុះបណ្តាលអាកាសចរណ៍ និងកម្មវិធីបណ្តុះបណ្តាល និងបញ្ជីឈ្មោះបុគ្គលដែលបានចាត់តាំងនិងទទួលស្គាល់
- ត្រួតពិនិត្យតាមដានការគ្រប់គ្រងក្នុងការផ្តល់ បដិសេធ ព្យួរ ដកហូត ពិន័យ វិញ្ញាបនបត្រឬអាជ្ញាបណ្ណអង្គភាពបណ្តុះបណ្តាលអាកាសចរណ៍ស៊ីវិលក្នុងនិងក្រៅប្រទេស ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ត្រួតពិនិត្យតាមដានលទ្ធផលការងាររបស់បុគ្គលដែលចាត់តាំងដោយរដ្ឋលេខាធិការដ្ឋាន និងប្រតិបត្តិករជាអ្នកត្រួតពិនិត្យសមត្ថភាពបច្ចេកទេស តំណាងឱ្យរដ្ឋលេខាធិការដ្ឋាន ដើម្បីដឹកនាំការប្រឡងសមត្ថភាពហោះហើររបស់អាកាសយានិក និងសមត្ថភាពបញ្ជាហោះហើររបស់បុគ្គលិកបញ្ជាចរាចរផ្លូវអាកាស
- សហការជាមួយនាយកដ្ឋានស្តង់ដាប្រតិបត្តិការហោះហើរ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធដទៃទៀត ក្នុងការពិនិត្យនិងវាយតម្លៃបច្ចេកទេសដើម្បីផ្តល់ បដិសេធ ផ្អាក ដកហូត និងបន្តសុពលភាពវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស

- ធានាថាអ្នកពិនិត្យសុខភាពនិងអ្នកវាយតម្លៃសុខភាព ត្រូវបានជ្រើសរើសនិងចាត់តាំងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិស្តីពីអាកាសចរណ៍ស៊ីវិលកម្ពុជានិងស្តង់ដារបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- ត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ បន្តសុពលភាព ពិន័យ ដកហូតការអនុញ្ញាតដល់អ្នកពិនិត្យសុខភាពដែលបានចាត់តាំង អ្នកវាយតម្លៃសុខភាព មន្ទីរពេទ្យឬគ្លីនិកដែលពិនិត្យសុខភាពក្រុមអាកាសយានិក បុគ្គលិកបញ្ជាចរាចរផ្លូវអាកាស និងបុគ្គលិកជំនាញអាកាសចរណ៍ដទៃទៀត
- ផ្តួចផ្តើមនិងដឹកនាំសិក្សាស្រាវជ្រាវក្នុងការងារអាជ្ញាបណ្ណដែលទាក់ទងនឹងសមាជិកក្រុមអាកាសយានិក វិស្វករថែរក្សាបច្ចេកទេសអាកាសយាន បុគ្គលិកបញ្ជាចរាចរផ្លូវអាកាស បុគ្គលិកប្រតិបត្តិការហោះហើរ និងអ្នកជំនាញពាក់ព័ន្ធដទៃទៀត
- ពិនិត្យ វិភាគ វាយតម្លៃសារធាតុញៀន ជាតិស្រវឹង ថ្នាំពេទ្យ ឬសារធាតុផ្សេងៗទៀត ដែលហាមឃាត់នៅពេលដែលមានការសង្ស័យឬពេលចាំបាច់យល់ឃើញថា ក្រុមអាកាសយានិក បុគ្គលិកបញ្ជាចរាចរផ្លូវអាកាស និងបុគ្គលិកអាកាសចរណ៍ណាម្នាក់ មានសតិស្មារតីមិនប្រក្រតី មុនពេលចូលនិងកំពុងធ្វើការងារ
- ត្រួតពិនិត្យតាមដានជាប្រចាំនិងធ្វើសវនកម្មលើអ្នកកាន់អាជ្ញាបណ្ណនិងកម្រិតជំនាញ និងអង្គភាពបណ្តុះបណ្តាលអាកាសចរណ៍ស៊ីវិលទាំងអស់ ឱ្យស្របតាមគោលការណ៍ នីតិវិធី និងបទប្បញ្ញត្តិស្តីពីអាកាសចរណ៍ស៊ីវិលកម្ពុជា
- សហការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេតគ្រោះថ្នាក់ឬឧប្បត្តិហេតុអាកាសចរណ៍នៅក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេសដែលទាក់ទងនឹងអាជ្ញាបណ្ណនិងកម្រិតជំនាញដើម្បីសុំការពិនិត្យនិងសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារអាជ្ញាបណ្ណបុគ្គលិក
- ទទួលខុសត្រូវលើការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

**មាត្រា២២ .-**

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- ធ្វើសហប្រតិបត្តិការ សម្របសម្រួល និងដើរតួនាទីជាចំណុចទាក់ទង លើរាល់ការងារជាមួយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ និងជាអង្គភាពសម្របសម្រួលថ្នាក់ជាតិលើកម្មវិធីសវនកម្មសន្តិសុខនិងសុវត្ថិភាពអាកាសចរណ៍សកល
- សម្របសម្រួលនិងចូលរួមអនុវត្តរាល់កិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យអាកាសចរណ៍ស៊ីវិលទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី រួមទាំងកិច្ចការអឺរ៉ុប អាស៊ាន អនុតំបន់ តំបន់ និងអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- រៀបចំនិងសម្របសម្រួលកិច្ចប្រជុំអន្តរជាតិនិងការធ្វើបដិសណ្ឋារកិច្ច ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ

- លើកសំណើ រៀបចំបែបបទ និងសម្របសម្រួលជូនថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃរដ្ឋលេខាធិការដ្ឋាន ដើម្បីចូលរួមកិច្ចប្រជុំ សន្និសីទ សន្និបាត សិក្ខាសាលា និងបេសកកម្មនានា ក្នុងក្របខ័ណ្ឌអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ អង្គការអន្តរជាតិ និងកិច្ចប្រជុំផ្សេងៗ
- ចូលរួមកិច្ចប្រជុំនានាក្នុងក្របខ័ណ្ឌអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ និងរាល់កិច្ចប្រជុំដែលពាក់ព័ន្ធនឹងគម្រោងសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមពិនិត្យនិងផ្តល់យោបល់លើឯកសារលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យអាកាសចរណ៍ស៊ីវិល
- រៀបចំនិងសម្របសម្រួលបម្រើការហោះហើរពិសេសជូនគណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងបណ្ណាល័យរបស់រដ្ឋលេខាធិការដ្ឋាន
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។

## ជំពូកទី៦
## អគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស

**មាត្រា២៣ .-**

អគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស មានតួនាទីដឹកនាំ គ្រប់គ្រង និងសម្របសម្រួលលើការងារកសាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ជំរុញការដឹកជញ្ជូនតាមផ្លូវអាកាស និងគាំទ្រឧស្សាហកម្មអាកាសចរណ៍ស៊ីវិល និងអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា២៤ .-**

អគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស មានរចនាសម្ព័ន្ធដូចតទៅ៖

១- នាយកដ្ឋានផែនការយុទ្ធសាស្ត្រ។

២- នាយកដ្ឋានជំរុញការដឹកជញ្ជូនតាមផ្លូវអាកាស។

៣- នាយកដ្ឋានគាំទ្រឧស្សាហកម្មអាកាសចរណ៍ស៊ីវិល។

**មាត្រា២៥ .-**

នាយកដ្ឋានផែនការយុទ្ធសាស្ត្រ មានភារកិច្ចដូចតទៅ៖

- រៀបចំកសាង ធ្វើបច្ចុប្បន្នភាព និងតាមដានការអនុវត្តគោលនយោបាយជាតិ គោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស ផែនការយុទ្ធសាស្ត្រ និងផែនការមេនៃការអភិវឌ្ឍវិស័យអាកាសចរណ៍ស៊ីវិល អនុលោមតាមច្បាប់ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវនិងវិភាគពីស្ថានភាពសេដ្ឋកិច្ច សន្តិសុខ សុវត្ថិភាព និងបរិស្ថាននៃវិស័យអាកាសចរណ៍ស៊ីវិល
- ចងក្រងនិងគ្រប់គ្រងទិន្នន័យស្ថិតិអាកាសចរណ៍ស៊ីវិល

- ពិនិត្យ ផ្តល់យោបល់ និងតាមដានការអនុវត្តគម្រោងសហប្រតិបត្តិការទាក់ទងនឹងវិស័យអាកាសចរណ៍ស៊ីវិល ជាមួយដៃគូអភិវឌ្ឍថ្នាក់ជាតិ អនុតំបន់ តំបន់ និងអន្តរជាតិ
- ចូលរួមពិនិត្យនិងវាយតម្លៃគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ស៊ីវិល ដោយអនុលោមទៅតាមគោលនយោបាយនិងផែនការដែលបានដាក់ចេញ
- ទទួលខុសត្រូវលើការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស។

**មាត្រា២៦ .-**

នាយកដ្ឋានជំរុញការដឹកជញ្ជូនតាមផ្លូវអាកាស មានភារកិច្ចដូចតទៅ៖

- រៀបចំ ចរចា និងបង្កើតអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- ចូលរួមគ្រប់គ្រងនិងចាត់ចែងលើការងារអាកាសចរណ៍ស៊ីវិលចាំបាច់មួយចំនួន ដូចជាសេរីភាវូបនីយកម្មសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ជាមួយសមាគមអាស៊ាននិងអង្គការដទៃផ្សេងទៀត ទាំងក្នុងកម្រិតតំបន់និងអន្តរជាតិ
- សិក្សានិងផ្តល់មតិយោបល់លើខ្លឹមសារនិងអត្ថន័យរបស់អនុស្សរណៈនៃការយោគយល់គ្នានិងកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាទ្វេភាគី ពហុភាគី និងអាស៊ាន
- រៀបចំនិងផ្តល់មតិយោបល់លើការបែងចែកសិទ្ធិហោះហើរនិងចំនួនជើងហោះហើរ ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក
- រៀបចំបែបបទដើម្បីផ្តល់សច្ចាប័ន ប្រគល់សិទ្ធិ និងចុះហត្ថលេខាអនុស្សរណៈយោគយល់និងកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស
- រៀបចំនិងចងក្រងឯកសារអនុស្សរណៈនៃការយោគយល់គ្នានិងកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាទ្វេភាគី ពហុភាគី និងអាស៊ាន
- វាយតម្លៃរាល់ពាក្យស្នើសុំចាត់តាំងនិងធ្វើលិខិតចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ជាតិ និងទទួលយកការចាត់តាំងក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិ ឱ្យស្របតាមអនុស្សរណៈនៃការយោគយល់គ្នានិងកិច្ចព្រមព្រៀង សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាទ្វេភាគី និងពហុភាគី ដែលចូលជាធរមាន
- វាយតម្លៃរាល់ពាក្យស្នើសុំរបស់ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ សម្រាប់ការហោះហើរជាលក្ខណៈពាណិជ្ជកម្មតាមកម្មវិធីនិងក្រៅកម្មវិធី
- គ្រប់គ្រងនិងបែងចែកស្លុតសម្រាប់ការចុះចតនិងហោះហើរឡើងនៃអាកាសយាន នៅតាមបណ្តាអាកាសយានដ្ឋានជាតិនិងអន្តរជាតិ
- ទទួលខុសត្រូវលើការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស។

**មាត្រា២៧ .-**

នាយកដ្ឋានគាំទ្រឧស្សាហកម្មអាកាសចរណ៍ស៊ីវិល មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិសេដ្ឋកិច្ចដឹកជញ្ជូនតាមផ្លូវអាកាស អនុលោមទៅតាមច្បាប់ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្មនិងនាយកដ្ឋានពាក់ព័ន្ធ
- ពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស
- ជួយគាំទ្រឱ្យមាននិរន្តរភាពទីផ្សារសេដ្ឋកិច្ចនិងប្រសិទ្ធភាពឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស
- រៀបចំផ្សព្វផ្សាយផលិតផលអាកាសចរណ៍ស៊ីវិល ដើម្បីជំរុញកំណើនការដឹកជញ្ជូនតាមផ្លូវអាកាស
- តាមដាននិងត្រួតពិនិត្យគុណភាពសេវាកម្មសហគ្រាសឧស្សាហកម្មអាកាសចរណ៍ស៊ីវិល
- តាមដាននិងត្រួតពិនិត្យការប្រកួតប្រជែងសហគ្រាសឧស្សាហកម្មអាកាសចរណ៍ស៊ីវិល
- ពិនិត្យ វាយតម្លៃ និងរៀបចំផ្តល់វិញ្ញាបនបត្រសហគ្រាសឧស្សាហកម្មអាកាសចរណ៍ស៊ីវិល ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ពិនិត្យ វាយតម្លៃ និងទទួលស្គាល់បណ្ណធានារ៉ាប់រងរបស់សហគ្រាសឧស្សាហកម្មអាកាសចរណ៍ស៊ីវិល
- ពិនិត្យ វាយតម្លៃ និងរៀបចំផ្តល់ការអនុញ្ញាតនាំចូលសម្ភារៈនិងបរិក្ខារអាកាសចរណ៍ស៊ីវិល
- ទទួលបណ្តឹង វិវាទ និងដោះស្រាយជូនក្រុមហ៊ុនអាកាសចរណ៍ អ្នកធ្វើដំណើរតាមផ្លូវអាកាស សហគ្រាសឧស្សាហកម្មអាកាសចរណ៍ស៊ីវិល ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- ទទួលខុសត្រូវលើការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស។

## ជំពូកទី៧
## អគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្ម

**មាត្រា២៨ .-**

អគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្មមានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលលើកិច្ចការសេវាកម្មអាកាសចរណ៍ ឧតុនិយមអាកាសចរណ៍ ការរុករកនិងសង្គ្រោះអាកាសចរណ៍ អាកាសយានដ្ឋានអន្តរជាតិ អាកាសយានដ្ឋានមូលដ្ឋាន និងអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា២៩ .-**

អគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្ម មានរចនាសម្ព័ន្ធដូចតទៅ៖

១- នាយកដ្ឋានគ្រប់គ្រងសេវាកម្មអាកាសចរណ៍។

២- នាយកដ្ឋានឧតុនិយមអាកាសចរណ៍។

៣- នាយកដ្ឋានរុករកនិងសង្គ្រោះអាកាសចរណ៍។

៤- អាកាសយានដ្ឋានអន្តរជាតិ ថ្នាក់ស្មើនាយកដ្ឋាន។

៥- អាកាសយានដ្ឋានមូលដ្ឋាន ថ្នាក់ស្មើការិយាល័យ។

**មាត្រា៣០.-**

នាយកដ្ឋានគ្រប់គ្រងសេវាកម្មអាកាសចរណ៍ មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្ត ដែលទាក់ទងនឹងការគ្រប់គ្រងសេវាកម្មគាំទ្រអាកាសចរណ៍ស៊ីវិល អនុលោមតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- សហការនិងសម្របសម្រួលជាមួយប្រតិបត្តិករផ្តល់សេវាកម្មនាំផ្លូវអាកាសលើការផ្តល់សេវាកម្មនាំផ្លូវអាកាស នៅក្នុង ចេញ ចូល និងឆ្លងកាត់ដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា
- សហការនិងសម្របសម្រួលជាមួយប្រតិបត្តិករអាកាសយានដ្ឋានលើការផ្តល់សេវាកម្មប្រតិបត្តិការអាកាសយានដ្ឋាន
- ចូលរួមពិនិត្យនិងវាយតម្លៃលើការអនុវត្តកិច្ចព្រមព្រៀង កិច្ចសន្យានានារវាងរាជរដ្ឋាភិបាលនិងប្រតិបត្តិករអាកាសយានដ្ឋាននិងប្រតិបត្តិករផ្តល់សេវាកម្មនាំផ្លូវអាកាស លើទិដ្ឋភាពពាក់ព័ន្ធនឹងការផ្តល់សេវាកម្មអាកាសចរណ៍
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងផ្តល់សេវាកម្មអាកាសចរណ៍ ដើម្បីសុំការពិនិត្យនិងសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី លើការងារផ្តល់សេវាកម្មអាកាសចរណ៍
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្ម។

**មាត្រា៣១.-**

នាយកដ្ឋានឧតុនិយមអាកាសចរណ៍ មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្មព័ត៌មានឧតុនិយមអាកាសចរណ៍ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- អនុវត្តច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានា ទាំងថ្នាក់ជាតិនិងអន្តរជាតិស្តីពីការផ្តល់សេវាកម្មព័ត៌មានឧតុនិយមអាកាសចរណ៍ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- ពិនិត្យនិងកែសម្រួលកម្រិតលម្អៀងលើប្រព័ន្ធនិងឧបករណ៍ឧតុនិយមអាកាសចរណ៍ ឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស
- គ្រប់គ្រងនិងផ្តល់សេវាកម្មព័ត៌មានឧតុនិយមអាកាសចរណ៍ ឱ្យស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិនិងស្តង់ដាអង្គការឧតុនិយមពិភពលោក
- ផ្តល់សេវាកម្មព័ត៌មានឧតុនិយមអាកាសចរណ៍ដល់ប្រតិបត្តិករនាំផ្លូវអាកាសនិងក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិដែលធ្វើប្រតិបត្តិការហោះហើរក្នុងនិងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលនិងផ្តល់ព័ត៌មានទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ ដោយសហការជាមួយនាយកដ្ឋាននិងអង្គភាពចំណុះរដ្ឋលេខាធិការដ្ឋាន ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងអន្តរជាតិ

- រៀបចំកិច្ចព្រមព្រៀងនិងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការផ្តល់សេវាកម្មព័ត៌មានឧតុនិយមអាកាសចរណ៍ជាមួយប្រតិបត្តិករអាកាសយានដ្ឋាន ប្រតិបត្តិករនាំផ្លូវអាកាស ក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងអន្តរជាតិ
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្មព័ត៌មានឧតុនិយមអាកាសចរណ៍ ដើម្បីស្នើសុំការពិនិត្យនិងសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី លើការងារផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្ម។

**មាត្រា៣២ .-**

នាយកដ្ឋានរុករកនិងសង្គ្រោះអាកាសចរណ៍ មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា លក្ខខណ្ឌតម្រូវ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការងាររុករកនិងសង្គ្រោះអាកាសចរណ៍ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិលកម្ពុជា ព្រមទាំងស្តង់ដានិងអនុសាសន៍អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- អនុវត្តច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ទាំងកម្រិតជាតិនិងអន្តរជាតិស្តីពីការផ្តល់សេវាកម្មសម្របសម្រួលរុករកនិងសង្គ្រោះលើវិស័យអាកាសចរណ៍ស៊ីវិល ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំនិងចងក្រងផែនការយុទ្ធសាស្ត្រនិងនីតិវិធីផ្តល់សេវាកម្មរុករកនិងសង្គ្រោះ
- រៀបចំយន្តការដើម្បីត្រៀមបង្ការទុកជាមុននូវសម្ភារៈ ឧបករណ៍ មធ្យោបាយ និងធនធានមនុស្សពេលមានគ្រោះអាសន្នកើតឡើង
- រៀបចំកិច្ចព្រមព្រៀងនិងអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរពាក់ព័ន្ធទាំងកម្រិតជាតិនិងអន្តរជាតិ លើការសម្របសម្រួលសង្គ្រោះ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំផែនការ កម្មវិធីហ្វឹកហ្វឺន និងការធ្វើសមយុទ្ធជាមួយក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរពាក់ព័ន្ធទាំងកម្រិតជាតិនិងអន្តរជាតិ
- សហប្រតិបត្តិការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងអន្តរជាតិ ក្នុងករណីដែលមានព្រឹត្តិការណ៍ឬឧបទ្ទវហេតុកើតឡើង ដូចជាគ្រោះថ្នាក់អាកាសយាននិងមនុស្សលើអាកាសយាន
- ទទួលខុសត្រូវចំពោះការផ្តល់សេវាកម្មរុករកនិងសង្គ្រោះដល់អាកាសយានបាត់ដំណឹងឬមានគ្រោះថ្នាក់និងមនុស្សនៅលើអាកាសយាននៅក្នុងព្រះរាជាណាចក្រកម្ពុជានិងតំបន់ដទៃទៀត ដែលព្រះរាជាណាចក្រកម្ពុជាទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មទាំងនេះ ដោយផ្អែកលើកិច្ចព្រមព្រៀងនាំផ្លូវអាកាសក្នុងតំបន់

- ទទួលខុសត្រូវសម្របសម្រួលសង្គ្រោះ ដើម្បីជំរុញការរៀបចំប្រកបដោយប្រសិទ្ធភាពនូវសេវាកម្មរុករកនិងសង្គ្រោះ និងដើម្បីសម្របសម្រួលកិច្ចប្រតិបត្តិការរុករកនិងសង្គ្រោះ ដែលតម្រូវឱ្យមានបុគ្គលិកប្រចាំការ២៤ម៉ោងក្នុងមួយថ្ងៃ ដែលមានការបណ្តុះបណ្តាលនិងលក្ខណសម្បត្តិគ្រប់គ្រាន់
- តាមដាននិងឃ្លាំមើលតាមប្រព័ន្ធផ្កាយរណបអំពីអាកាសយាននិងមនុស្សនៅលើអាកាសយានក្នុងករណីដែលមានគ្រោះអាសន្នកើតឡើង
- រាយការណ៍បន្ទាន់អំពីស្ថានភាពគ្រោះថ្នាក់អាកាសយាននិងមនុស្សលើអាកាសយាន ជូនថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី លើការងារផ្តល់សេវាកម្មរុករកនិងសង្គ្រោះ
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្ម។

**មាត្រា៣៣ .-**

អាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- ជាតំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្នុងការសម្របសម្រួលកិច្ចប្រតិបត្តិការនិងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងនិងជុំវិញអាកាសយានដ្ឋានអន្តរជាតិ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធនានា ក្នុងការរៀបចំការពារនិងធ្វើបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ គណៈប្រតិភូជាតិនិងអន្តរជាតិដែលទៅបំពេញបេសកកម្មនៅក្រៅប្រទេសនិងមកបំពេញបេសកកម្មនៅកម្ពុជា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធនានា ក្នុងការដឹកនាំធ្វើលំហាត់សមយុទ្ធគ្រប់គ្រងគ្រោះអាសន្នឱ្យបានទៀងទាត់
- ចូលរួមផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងការគ្រប់គ្រងប្រតិបត្តិការនិងការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារគ្រប់គ្រងប្រតិបត្តិការនិងការអភិវឌ្ឍអាកាសយានដ្ឋាន
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានប្រតិបត្តិការនិងសេវាកម្ម។

## ជំពូកទី៨
## ការបង្កើតអាកាសយានដ្ឋាន

**មាត្រា៣៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចស្នើសុំបង្កើតអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន តាមការចាំបាច់។

ការបង្កើតអាកាសយានដ្ឋានអន្តរជាតិនានា ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបង្កើតអាកាសយានដ្ឋានមូលដ្ឋាននានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បន្ទាប់ពីទទួលបានការឯកភាពជាមុនពីរាជរដ្ឋាភិបាល។

## ជំពូកទី៩
## វិទ្យាស្ថានជាតិអាកាសចរណ៍ស៊ីវិល

**មាត្រា៣៥ .-**

វិទ្យាស្ថានជាតិអាកាសចរណ៍ស៊ីវិល សរសេរជាអក្សរកាត់ថា**វ.ជ.អ.ស.** បំពេញមុខងារជាសេនាធិការឱ្យរដ្ឋលេខាធិការដ្ឋានលើការងារបណ្ដុះបណ្ដាល ស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យអាកាសចរណ៍ស៊ីវិលដល់មន្ត្រីរាជការនិងនិស្សិត ស្របតាមតម្រូវការជាតិនិងអន្តរជាតិ។

**វ.ជ.អ.ស.**មានរូបសញ្ញានិងត្រាដោយឡែកសម្រាប់ដំណើរការរបស់ខ្លួន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៣៦ .-**

**វ.ជ.អ.ស.**មានរចនាសម្ព័ន្ធដូចតទៅ៖

១- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

២- នាយកដ្ឋានផែនការនិងអភិវឌ្ឍន៍។

៣- នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ។

**មាត្រា៣៧ .-**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងលិខិតចេញ ចូលរបស់**វ.ជ.អ.ស.** និងចរាចរលិខិតរដ្ឋបាលទៅតាមមុខសញ្ញា
- គ្រប់គ្រងត្រារបស់**វ.ជ.អ.ស.**
- គ្រប់គ្រងសន្តិសុខ សណ្ដាប់ធ្នាប់ អនាម័យ ព្រមទាំងការពារទ្រព្យសម្បត្តិនិងសម្ភារៈបរិក្ខាររបស់**វ.ជ.អ.ស.**
- រៀបចំនិងគ្រប់គ្រងសំណុំលិខិតមន្ត្រីរាជការ បុគ្គលិក និងមន្ត្រីជាប់កិច្ចសន្យារបស់**វ.ជ.អ.ស.**
- រៀបចំទម្រង់បែបបទនិងធ្វើលិខិតបទដ្ឋានផ្សេងៗរបស់**វ.ជ.អ.ស.**
- បំពេញបែបបទនិងផ្លាស់ប្ដូរកន្លែងបំពេញការងាររបស់មន្ត្រីរាជការ បុគ្គលិករបស់**វ.ជ.អ.ស.** តាមនីតិវិធីជាធរមាន
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនិងកិច្ចប្រជុំផ្សេងៗ ព្រមទាំងធ្វើរបាយការណ៍ឬកំណត់ហេតុប្រជុំរបស់**វ.ជ.អ.ស.**
- គ្រប់គ្រងការងារលើកទឹកចិត្តនិងវិន័យ ដែលមានចែងក្នុងច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងបណ្ណាល័យរបស់**វ.ជ.អ.ស.**
- សហការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងលើកគម្រោងកម្មវិធីចំណាយ ចំណូល កិច្ចបញ្ជិកាគណនេយ្យ កស្ដុភារ និងបញ្ជីសារពើភណ្ឌរបស់**វ.ជ.អ.ស.**
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល

- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយក**វ.ជ.អ.ស.**។

**មាត្រា៣៨ .-**

នាយកដ្ឋានផែនការនិងអភិវឌ្ឍន៍ មានភារកិច្ចដូចតទៅ៖

- សហប្រតិបត្តិការជាមួយនាយកដ្ឋានគ្រប់គ្រងធនធានមនុស្សអំពីតម្រូវការនិងលើកផែនការបណ្តុះបណ្តាល
- ធ្វើផែនការសិក្សាស្រាវជ្រាវ និងកំណត់អាទិភាពតម្រូវការបណ្តុះបណ្តាលនិងវគ្គវិក្រឹតការនានា
- រៀបចំចងក្រង បោះពុម្ពឯកសារ ព្រឹត្តិបត្រព័ត៌មាន ឯកសារផ្សព្វផ្សាយ ទស្សនាវដ្តីរបស់**វ.ជ.អ.ស.**
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិ ដើម្បីស្វែងរកជំនួយ សម្ភារៈ ហិរញ្ញវត្ថុ និងជំនួយផ្សេងៗ
- ទំនាក់ទំនងជាមួយស្ថាប័ននានាអំពីតម្រូវការបណ្តុះបណ្តាល
- គ្រប់គ្រងនិងផ្សព្វផ្សាយអំពី**វ.ជ.អ.ស.**ឱ្យបានជ្រួតជ្រាបដល់សិស្ស និស្សិត និងស្ថាប័ននានាអំពីលទ្ធភាពបណ្តុះបណ្តាលរបស់**វ.ជ.អ.ស.**
- រៀបចំចងក្រងឯកសារផ្សេងៗ ដើម្បីឆ្លើយតបតម្រូវការស្ថាប័នជាតិនិងអន្តរជាតិ
- សហការជាមួយនាយកដ្ឋាននានា ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីតម្រូវការបណ្តុះបណ្តាលនិងអភិវឌ្ឍកម្មវិធីសិក្សានិងវគ្គវិក្រឹតការ
- រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ស្តីពីការត្រួតពិនិត្យគុណភាពប្រតិបត្តិការបណ្តុះបណ្តាលដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- ត្រួតពិនិត្យគុណភាពកម្មវិធីនិងការអនុវត្តការងារបណ្តុះបណ្តាលរបស់**វ.ជ.អ.ស.**
- រៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់**វ.ជ.អ.ស.** ស្របតាមស្តង់ដាជាតិនិងអន្តរជាតិ
- ធ្វើអធិការកិច្ចផ្ទៃក្នុងរបស់**វ.ជ.អ.ស.**
- ទទួលខុសត្រូវចំពោះសវនកម្មថ្នាក់ជាតិនិងអន្តរជាតិពាក់ព័ន្ធជាអាទិ៍មានសវនកម្មរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាគមដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ទទួលបន្ទុកបណ្តុះបណ្តាលនិងអង្គការស្តង់ដាអន្តរជាតិ
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយក**វ.ជ.អ.ស.**។

**មាត្រា៣៩ .-**

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ មានភារកិច្ចដូចតទៅ៖

- អនុវត្តតាមកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការរបស់**វ.ជ.អ.ស.**
- ផ្តល់សេវាកម្មបណ្តុះបណ្តាលបន្ត តាមរយៈវគ្គវិក្រឹតការនិងវគ្គសិក្សាខ្លីៗ
- ផ្តល់សេវាកម្មបណ្តុះបណ្តាលលើជំនាញគ្រប់គ្រង ជំនាញបច្ចេកទេស និងជំនាញគាំទ្រវិស័យអាកាសចរណ៍ស៊ីវិល ទាំងកម្រិតបឋម កម្រិតមធ្យម និងកម្រិតឧត្តម ដល់សិស្ស និស្សិត មន្ត្រីរាជការ និងបុគ្គលិកក្រុមហ៊ុនឯកជន
- រៀបចំចងក្រងឯកសារបណ្តុះបណ្តាលនិងវិក្រឹតការសម្រាប់សិស្ស និស្សិត ឬសិក្ខាកាមរយៈពេលខ្លី មធ្យម និងវែង ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ**វ.ជ.អ.ស.**

- រៀបចំធ្វើតេស្តសមត្ថភាពសិស្ស និស្សិត
- រៀបចំកាលវិភាគបង្រៀនរបស់គ្រូ សាស្ត្រាចារ្យ
- រៀបចំកម្មវិធីប្រឡងបញ្ចប់តាមមុខជំនាញនីមួយៗ និងកម្មវិធីការពារសារណាឬរបាយការណ៍បញ្ចប់វគ្គសិក្សា
- រៀបចំវិញ្ញាបនបត្រ សញ្ញាបត្រ លិខិតបញ្ជាក់ការសិក្សា និងព្រឹត្តិបត្រពិន្ទុជូនសិស្ស និស្សិត
- រៀបចំនីតិវិធីជ្រើសរើសនិងចុះបញ្ជីគ្រូ សាស្ត្រាចារ្យ ដែលមានប្រភពក្នុងនិងក្រៅវ.ជ.អ.ស.
- ទទួលខុសត្រូវសវនកម្មនានា
- រៀបចំនិងសម្របសម្រួលកម្មវិធីបណ្តុះបណ្តាល ទស្សនកិច្ចរបស់សិស្ស និស្សិត និងមន្ត្រីរាជការ
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវ.ជ.អ.ស.។

## ជំពូកទី១០
## នាយកដ្ឋាននីតិកម្ម

**មាត្រា៤០ ..**

នាយកដ្ឋាននីតិកម្ម មានភារកិច្ចដូចតទៅ៖

- សិក្សា រៀបចំតាក់តែង ធ្វើវិសោធនកម្ម កែសម្រួលសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិលទាំងមូល អនុលោមទៅតាមច្បាប់និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
- ចូលរួមពិនិត្យផ្តល់យោបល់លើការតាក់តែងឬការកែសម្រួលឯកសារគតិយុត្ត ដូចជាកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា កិច្ចសន្យា សេចក្តីកំណត់ និងសេចក្តីណែនាំទាំងឡាយ ដែលបម្រើឱ្យផលប្រយោជន៍របស់រដ្ឋលេខាធិការដ្ឋាន
- ចូលរួមចរចានិងរៀបចំសន្ធិសញ្ញា អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិល
- ពិនិត្យនិងផ្តល់យោបល់លើទិដ្ឋភាពច្បាប់ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើវិស័យអាកាសចរណ៍ស៊ីវិល ទាំងថ្នាក់ជាតិនិងអន្តរជាតិ
- សិក្សាស្រាវជ្រាវច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងឯកសារសំខាន់ៗ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើបច្ចុប្បន្នកម្មនិងសិក្សាវាយតម្លៃលើផលប៉ះពាល់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិល
- ពិនិត្យនិងផ្តល់យោបល់លើការអនុវត្តនីតិវិធីដាក់ទណ្ឌកម្មលើសកម្មភាពបំពានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិអាកាសចរណ៍ស៊ីវិល
- ផ្សព្វផ្សាយ ត្រួតពិនិត្យ និងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យអាកាសចរណ៍ស៊ីវិល
- គ្រប់គ្រង ចងក្រង បោះពុម្ពផ្សព្វផ្សាយ និងតម្កល់ទុកឯកសារច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងឯកសារនិងបទប្បញ្ញត្តិរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ និងឯកសារ

សំខាន់ៗពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្ត វិធាននានា និងឯកសារគាំទ្របម្រើឱ្យផលប្រយោជន៍វិស័យអាកាសចរណ៍ស៊ីវិល

- រៀបចំផែនការវគ្គបណ្តុះបណ្តាលទាក់ទងនឹងការងារនីតិកម្មក្នុងវិស័យអាកាសចរណ៍ស៊ីវិល
- សម្របសម្រួល ផ្សះផ្សា និងដោះស្រាយវិវាទអាកាសចរណ៍ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនៃរដ្ឋលេខាធិការដ្ឋាននិងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ពិនិត្យនិងផ្តល់យោបល់លើការងារដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការលើកិច្ចការនីតិកម្ម និងសុំការសម្រេចពីថ្នាក់ដឹកនាំ
- ចូលរួមជាផ្នែកគាំទ្រក្នុងគ្រប់កម្មវិធីកំណែទម្រង់ ក្នុងក្របខ័ណ្ឌរដ្ឋលេខាធិការដ្ឋាន និងជាផ្នែកប្រតិបត្តិសម្រាប់ការងារពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

## ជំពូកទី១១
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៤១ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ច ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១២
## អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍

**មាត្រា៤២ .-**

អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ មានភារកិច្ចដូចតទៅ៖

- រៀបចំនិងចងក្រងបទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងកិច្ចការស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ អនុលោមតាមច្បាប់និងលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- ចូលរួមស៊ើបអង្កេតនិងវាយតម្លៃឧប្បត្តិហេតុឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍ ដោយសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិពាក់ព័ន្ធ
- ស៊ើបអង្កេតឧប្បត្តិហេតុឬគ្រោះថ្នាក់ពាក់ព័ន្ធដល់អាកាសយាន ទាំងក្នុងនិងក្រៅប្រទេស ដែលបានចុះបញ្ជីនៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដោយសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិពាក់ព័ន្ធ
- ទទួលខុសត្រូវនិងសហការរៀបចំនិងអនុវត្តរាល់កិច្ចព្រមព្រៀងស្តីពីឧប្បត្តិហេតុឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍
- ត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលស៊ើបអង្កេតនិងគ្រប់គ្រងព័ត៌មាន

- រៀបចំផែនការទប់ស្កាត់ឧប្បត្តិហេតុឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងឧប្បត្តិហេតុឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍និងសុំការសម្រេចពីថ្នាក់ដឹកនាំ
- រៀបចំកម្មវិធីនិងផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើការងារស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍
- ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចនិងសវនកម្មលើវិស័យអាកាសចរណ៍ស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

## ជំពូកទី១៣
## ថវិកានិងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៤៣ .-**

ការរៀបចំនិងការអនុវត្តថវិការបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវអនុវត្តផ្អែកលើទំហំឥណទាននិងមុខសញ្ញាថវិកា ដែលត្រូវបានអនុម័តក្នុងច្បាប់ថវិកាប្រចាំឆ្នាំសម្រាប់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិនិងហិរញ្ញវត្ថុរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។

**មាត្រា៤៤ .-**

រាល់ឯកសារ ព័ត៌មាន និងទិន្នន័យដែលត្រូវបានរៀបចំ ប្រើប្រាស់ និងបម្រុងប្រើប្រាស់សម្រាប់ការអនុវត្តមុខងារនិងភារកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ថ្នាក់ដឹកនាំនិងមន្ត្រីនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវចាត់ចែង គ្រប់គ្រង និងរក្សាទុករាល់ឯកសារ ព័ត៌មាន និងទិន្នន័យនៅក្នុងអង្គភាព ដោយមិនត្រូវធ្វើឱ្យខូចខាត ឬធ្វើឱ្យបាត់បង់ ឬធ្វើឱ្យបែកធ្លាយទៅខាងក្រៅដោយប្រការណាមួយឡើយ និងត្រូវប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារនិងភារកិច្ចដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

**មាត្រា៤៥ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទនិងការតែងតាំងមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវបន្តមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មន្ត្រីរាជការស៊ីវិលនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដែលត្រូវប៉ះពាល់ដោយការរៀបចំនិងកែសម្រួលរចនាសម្ព័ន្ធថ្មីស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវរក្សាទុកអត្ថប្រយោជន៍ផ្នែកបៀវត្សយ៉ាងហោចក្នុងកម្រិតដដែល។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា៤៦ .-**

អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ ស្តីពីការស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងចំណុះរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការប្រែក្លាយនិងដំឡើងមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរណ៍ស៊ីវិលទៅជាវិទ្យាស្ថានជាតិអាកាសចរណ៍ស៊ីវិល មានឋានៈស្មើអគ្គនាយកដ្ឋាន អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ស្តីពីការប្រែក្លាយនិងដំឡើងនាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាសទៅជាអគ្គនាយកដ្ឋានគោលនយោបាយនិងបទប្បញ្ញត្តិដឹកជញ្ជូនតាមផ្លូវអាកាសនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .–**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២៤ | ឥណទានមុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មីក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | <u>ការផ្ទេរចេញ</u> | | | | <u>1.100.000</u> | |
| | **៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា និងចំណាយមិនបានគ្រោងទុក** | | | | 1.100.000 | |
| 69 | ចំណាយមិនបានគ្រោងទុក | 2.454.267.000 | 2.396.326.100 | - | 1.100.000 | 2.395.226.100 |
| | <u>ការផ្ទេរចូល</u> | | | <u>1.100.000</u> | | |
| | **១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | | 600.000 | | |
| 65 | ឧបត្ថម្ភធន (មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកណ្តាល) | 30.105.000 | 4.386.303.700 | 600.000 | - | 4.386.903.700 |
| | **១២-ក្រសួងសុខាភិបាល** | | | 500.000 | | |
| 65 | ឧបត្ថម្ភធន (មន្ទីរពេទ្យជាតិ តេជោសន្តិភាព) | 119.895.000 | 119.895.000 | 500.000 | - | 120.395.000 |

**មាត្រា២ .–**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនី និងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

១)-ផ្តល់ជូនមន្ទីរពេទ្យតេជោសែនកោះធំ ស្ថិតក្រោមមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកណ្តាលចំនួន **៦០០ លានរៀល** សម្រាប់ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងវិសាលភាពនៃការពិនិត្យព្យាបាល ដើម្បីតំឡើងកម្រិតពីមន្ទីរពេទ្យបង្អែកកម្រិត ២ ទៅមន្ទីរពេទ្យបង្អែកកម្រិត ៣។

២)-ផ្តល់ជូនមន្ទីរពេទ្យជាតិ តេជោសន្តិភាព នៃក្រសួងសុខាភិបាលចំនួន ៥០០ លានរៀល សម្រាប់ទិញរថយន្ត Pick Up ចំនួន ១ គ្រឿង និងរថយន្ត Van ចំនួន ១ គ្រឿង។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់**ធិបឌិន្ទ** ជូនលោក ម៉ក់ គឹមជាន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវត្តសន្តិវង្សារាម កន្លងមក។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួនត្រូវទទួល បន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៦១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ៣៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវត្តសន្តិវង្សារាម កន្លងមកដូចមានរាយនាមខាងក្រោម៖

ក- មេដាយ **មាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | លោក | អ៊ុក ជី | នាយកសាលាបឋមសិក្សា៧មករា |
| ២- | លោក | ប៊ី ធឿន | នាយកសាលាបឋមសិក្សា០៦ |
| ៣- | ឧបាសក | អ៊ុន អិន់ | អាចារ្យវត្ត |
| ៤- | ឧបាសក | នួន សិទ្ធ | អាចារ្យវត្ត |
| ៥- | ឧបាសក | អេង ធឿន | អាចារ្យវត្ត |
| ៦- | ឧបាសក | តន់ លឿ | គណៈកម្មការវត្ត |
| ៧- | ឧបាសក | នី សុខហឿន | គណៈកម្មការវត្ត |
| ៨- | ឧបាសក | ហែម ចំរើន | គណៈកម្មការវត្ត |
| ៩- | ឧបាសក | ទូច តាំង | គណៈកម្មការវត្ត |
| ១០- | ឧបាសក | ប្រាក់ សារិទ្ធ | គណៈកម្មការវត្ត |
| ១១- | ឧបាសក | ទាវ តន | គណៈកម្មការវត្ត/. |

ខ- មេដាយ **ប្រាក់ស្ថាបនាជាតិ**

១- លោក ឈឹម ភិរក្ស ប្រធានមណ្ឌលបច្ចេកទេស
២- លោក លឹម ម៉េងហៃ មេភូមិបច្ចេកទេសភូមិ១៤
៣- លោក មុត សុទ្ធា មេភូមិបច្ចេកទេសភូមិ១៥
៤- លោក ម៉ិល វឿន សប្បុរសជន
៥- ឧបាសក ទូន សាម៉េត សប្បុរសជន

គ- មេដាយ **សំរឹទ្ធស្ថាបនាជាតិ**

១- លោក កែវ ផៃលាក មេឃុំជប់
២- អនុសេនីយ៍ឯក យ៉ង់ ចិន្តា នាយប៉ុស្តិ៍នគរបាលរដ្ឋបាលជប់
៣- លោកស្រី ហោ ស៊ិនណារី នាយិកាសាលាមតេយ្យពាមករា
៤- លោក វង្ស តារា មេភូមិ៤៦
៥- លោកស្រី មួង សុខឃីម មេភូមិជប់ទី២
៦- លោក ឡាត់ លាន មេភូមិច្រកចំបក់
៧- លោក ជា វ៉ាន់នី មេភូមិ០៦
៨- លោក ជា វិចិត្រ មេភូមិ៤៦
៩- លោក សន ប៊ុនណាត មេភូមិ១៥
១០- លោក ម៉ូវ គឹមយន់ មេភូមិ១៨
១១- ឧបាសក សន ផល្លប អាចារ្យវត្ត
១២- ឧបាសក យឹង សៀក អាចារ្យវត្ត
១៣- ឧបាសក គង់ ធន អាចារ្យវត្ត
១៤- ឧបាសក ជា សាអែម គណៈកម្មការវត្ត
១៥- ឧបាសកា ម៉ៅ សាខន គណៈកម្មការវត្ត
១៦- លោកស្រី មាស មុនីរ័ត្ន សប្បុរសជន
១៧- លោកស្រី ស៊ា មុយហ៊ួរ សប្បុរសជន
១៨- ឧបាសិកា ដួង សេងហួ សប្បុរសជន

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួនត្រូវទទួល បន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .–**

ដាក់ឱ្យចូលនិវត្តន៍នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២១រូប ដូចមានរាយនាមខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **ហាស់** | **ស៊ីថា** | អត្តលេខ | ០១៨៧៨ |
| ២- | វរសេនីយ៍ឯក | **ឈួន** | **យឿង** | អត្តលេខ | ០២៧២៣ |
| ៣- | វរសេនីយ៍ឯក | **ម៉ែន** | **ប៊ុនធឿន** | អត្តលេខ | ០៦៣១១ |
| ៤- | វរសេនីយ៍ឯក | **ស៊ិន** | **សុខា** | អត្តលេខ | ០៦៥១៤ |
| ៥- | វរសេនីយ៍ឯក | **ឈាង** | **សួ** | អត្តលេខ | ០៧២១៥ |
| ៦- | វរសេនីយ៍ឯក | **ខ្មៅ** | **ណូន** | អត្តលេខ | ០៧៣០៣ |
| ៧- | វរសេនីយ៍ឯក | **ឡូ** | **តឹកប៊ុន** | អត្តលេខ | ០៨៣៦០ |
| ៨- | វរសេនីយ៍ឯក | **មិ** | **សំអុល** | អត្តលេខ | ១២១៧៣ |
| ៩- | វរសេនីយ៍ឯក | **ហ៊ឹម** | **ចាន់** | អត្តលេខ | ១២២៥៧ |
| ១០- | វរសេនីយ៍ឯក | **សុខ** | **សំអាន** | អត្តលេខ | ១២៤៤៤ |
| ១១- | វរសេនីយ៍ឯក | **តូច** | **ភី** | អត្តលេខ | ១៤៦០៦ |
| ១២- | វរសេនីយ៍ឯក | **រាជ** | **សុផល** | អត្តលេខ | ១៤៨៣៩ |
| ១៣- | វរសេនីយ៍ឯក | **ប្រាក់** | **វិបុលជ័យ** | អត្តលេខ | ១៦២៤២ |
| ១៤- | វរសេនីយ៍ឯក | **ហ៊ា** | **សុខុន** | អត្តលេខ | ១៦២៧៧ |
| ១៥- | វរសេនីយ៍ឯក | **ហួត** | **គឹម** | អត្តលេខ | ២០៤១៧ |
| ១៦- | វរសេនីយ៍ឯក | **ជួង** | **ម៉ាន់** | អត្តលេខ | ២១១២៣ |
| ១៧- | វរសេនីយ៍ឯក | **ហួយ** | **ស្រ៊ុន** | អត្តលេខ | ៣៤១៩៤ |
| ១៨- | វរសេនីយ៍ឯក | **គង់** | **សុធន** | អត្តលេខ | ៣៤២៥១ |
| ១៩- | វរសេនីយ៍ឯក | **ទេព** | **សម្បត្តិ** | អត្តលេខ | ៣៤៣១១ |
| ២០- | វរសេនីយ៍ឯក | **ឈន** | **ណាងតិច** | អត្តលេខ | ៣៧១៤៧ |
| ២១- | វរសេនីយ៍ឯក | **ទ័ន** | **សុផន** | អត្តលេខ | ៤០២៣៣។ |

**មាត្រា២ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ១០កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៤ សសរ

### សេចក្តីសម្រេច
### ស្តីពី
### ការកែសម្រួលសមាសភាព
### ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ និងខេត្តស្វាយរៀង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ ២១៥ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ
- បានឃើញសេចក្តីសម្រេចលេខ ២០៤ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលសមាសភាពពីសមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ មកជាសមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម៖

១. លោកជំទាវ វង់ មយូរា រដ្ឋលេខាធិការ ក្រសួងអធិការកិច្ច

២. លោកស្រី កែវ កេសី អគ្គនាយករង នៃក្រសួងអធិការកិច្ច

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តពាក់ព័ន្ធ រដ្ឋបាលខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៩កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០២៤

**អប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥៤ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការកែសម្រួលសមាសភាព**
**ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត និងខេត្តកណ្តាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ ២១៤ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត
- បានឃើញសេចក្តីសម្រេចលេខ ២២២ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សម្រេច**

**ប្រការ១ .-**

ត្រូវបានកែសម្រួល លោកជំទាវ ប៊ុន នារី អគ្គនាយករង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីសមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត មកជាសមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល។

**ប្រការ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តពាក់ព័ន្ធ រដ្ឋបាលខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០២៤

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៦៥ សហវ.ប្រក

ប្រកាស
ស្តីពី
ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ នងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតនៅក្រោមនិវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា "គ.ប.អ."។

**ប្រការ២.-**

គ.ប.អ. មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.លោកជំទាវ | **កែវ ចរិយា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២.ឯកឧត្តម | **យ៉ែត ទីណែល** | អនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | អនុប្រធាន |
| ៣.ឯកឧត្តម | **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគាំពារសង្គម | អនុប្រធាន |
| ៤.ឯកឧត្តម | **ស៊ាន ផល្លា** | អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម | អនុប្រធាន |
| ៥.លោកជំទាវ | **រស់ ច័ន្ទស្រស់** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៦.ឯកឧត្តម | **ឯក ចន្ថា** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧.ឯកឧត្តម | **វង្ស ម៉ិនឥន្ទ្រាវុធ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន រតនាគារជាតិ | សមាជិក |
| ៨.ឯកឧត្តម | **ហាច រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៩.ឯកឧត្តម | **កែវ ម៉េងឡន់** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ១០.ឯកឧត្តម | **ឈឹម សារ៉េត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន លទ្ធកម្មសាធារណៈ | សមាជិក |
| ១១.ឯកឧត្តម | **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១២.ឯកឧត្តម | **ជា ទុមណា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន សវនកម្មផ្ទៃក្នុង | សមាជិក |
| ១៣.ឯកឧត្តម | **អ៊ុំ ស៊ីធ៊ីរ៉ា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | សមាជិក |
| ១៤.ឯកឧត្តម | **ឆាយ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៥.ឯកឧត្តម | **ស៊ូ សុជាតិ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ១៦.ឯកឧត្តម | **ឈួន សំរិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| ១៧.ឯកឧត្តម | **អ៊ិន សេម** | នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៨.ឯកឧត្តម | **ខិម ម៉ាក់ឆារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន | សមាជិក |

| | | | |
|---|---|---|---|
| ១៩.ឯកឧត្តម | តាំង ខួនលី | អគ្គនាយក នៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល | សមាជិក |
| ២០.ឯកឧត្តម | មន្ត ប្រាជ្ញា | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ២១.ឯកឧត្តម | អ៊ុំ លុយណា | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ២២.ឯកឧត្តម | ស៊ីសុវត្ថិ ដួងចំន្ទតោ | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | សមាជិក |
| ២៣.ឯកឧត្តម | រស់ គីរុណា | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ២៤.ឯកឧត្តម | គគី សម្បូរណ៍ | អគ្គនាយក នៃទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ | សមាជិក |
| ២៥. ឯកឧត្តម | សុខ ដារ៉ា | អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| ២៦.ឯកឧត្តម | ឈុន សម្បត្តិ | ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ២៧.ឯកឧត្តម | ម៉ូ ថារិន | អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្ម | សមាជិក |
| ២៨.ឯកឧត្តម | ម៉ូ ចំន្ទគីរូ | អគ្គនាយក នៃនិយ័តករធានារ៉ាប់រង | សមាជិក |
| ២៩.ឯកឧត្តម | ជុំ វណ្ណៈ | អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | សមាជិក |
| ៣០.លោក | ម៉ៅ ដាវ៉ឡេន | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ៣១.លោក | ហ៊ឹម ម៉ុនធឿន | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៣២.លោកបណ្ឌិត | សង់ ស៊ីណាទិត្យ | ប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក។ |

**ប្រការ៣...**

គ.ប.អ. មានភារកិច្ចដូចតទៅ៖

- សហការ និងសម្របសម្រួលជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ពាក់ព័ន្ធនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងអំពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ដល់មន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍លទ្ធផលប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ពាក់ព័ន្ធនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវចូលរួមប្រជុំតាមការអញ្ជើញ ឬសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- អនុវត្តការងារផ្សេងៗទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.--**

សមាសភាពនៃ គ.ម.អ. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ការប្រជុំអាចដឹកនាំដោយអនុប្រធានម្នាក់ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ៥.--**

គ.ម.អ. ត្រូវមានលេខាធិការដ្ឋានជាសេនាធិការ ដើម្បីសម្របសម្រួល និងអនុវត្តរាល់ការងារពាក់ព័ន្ធនឹងការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍។ សមាសភាព តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃ គ.ម.អ. ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន គ.ម.អ.។

**ប្រការ៦.--**

គ.ម.អ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៧.--**

ប្រកាសលេខ ១៥៨ សហវ.ប្រក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ ស្ដីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.--**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងប្រធានអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ[illegible] បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤១០ ..... [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសេចក្តីជូនដំណឹងលេខ០២៦/២៣ ហ.ត.ស.ព ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតរោងចក្រផលិតអំពូលភ្លើង សម្ភារប្រើប្រាស់ក្នុងផ្ទះ បន្ទប់ទឹក និងគ្រឿងបង្គុំរាំងនន របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតអំពូលភ្លើង សម្ភារប្រើប្រាស់ក្នុងផ្ទះ បន្ទប់ទឹក និងគ្រឿងបង្គុំរាំងនន ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន វ៉ាំងម៉ៅ (ខេមបូឌា) ហូមវែរ ឯ.ក

## <u>សម្រេច</u>

<u>**ប្រការ១៖**</u> អនុញ្ញាតឱ្យក្រុមហ៊ុន **វ៉ាំងម៉ៅ (ខេមបូឌា) ហូមវែរ** ឯ.ក **(WANGMAO (CAMBODIA) HOMEWARE CO., LTD.)** តំណាងដោយលោក **CHENG, ZHIHUA** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EB0744831** ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ បង្កើតរោងចក្រ**ផលិតអំពូលភ្លើង សម្ភារប្រើប្រាស់ក្នុងផ្ទះ បន្ទប់ទឹក និងគ្រឿងបង្គុំ រាំងនន** ដែលមានទីតាំងស្ថិតនៅ**តំបន់សេដ្ឋកិច្ចពិសេស ប៉ាយ ផាក (ផ្លូវជាតិលេខ១ ភូមិដំបូកជ្ជូរ សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង)**។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| **១- អំពូលភ្លើង** | ២៧៤០ |
| **២- សម្ភារប្រើប្រាស់ក្នុងផ្ទះ (Wheel Barrow)** | ២៨១៦ |
| **៣- សម្ភារប្រើប្រាស់ក្នុងផ្ទះ បន្ទប់ទឹក គ្រឿងបង្គុំរាំងនន** | ៣២៩០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតអំពូលភ្លើង សម្ភារប្រើប្រាស់ក្នុងផ្ទះ បន្ទប់ទឹក និងគ្រឿងបង្គុំរាំងនន វ៉ាងម៉ៅ (ខេមបូឌា) ហូមវែរ ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហេង សុខគង់

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -ខុទ្ទកាល័យរដ្ឋមន្ត្រី
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តស្វាយរៀង
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង
- -អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ហាយ ផាក
- -រដ្ឋបាលក្រុងបាវិត
- -រដ្ឋបាលសង្កាត់ប្រាសាទ

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤១១ ...ក.ឧ.ស.អ...គ.ក. ប្រ.ក

ថ្ងៃ...................... ខែ.......... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១០..... ខែ..វិច្ឆិកា..... ឆ្នាំ២០២៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៣៦៦៧/២៣ ក.អ.ក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបង្កើតរោងចក្រផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះពីលោហធាតុកែច្នៃ (ធ្នើរ) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះពីលោហធាតុកែច្នៃ (ធ្នើរ) ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ប្រាយម៍ ស្តរេច សឹលូសិន (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ប្រាយម៍ ស្តរេច សឹលូសិន (ខេមបូឌា) ឯ.ក (PRIME STORAGE SOLUTION (CAMBODIA) CO., LTD.) តំណាងដោយលោក TANG, YANG សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខE16958931 ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ បង្កើតរោងចក្រផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះពីលោហធាតុកែច្នៃ (ធ្នើរ) ដែលមានទីតាំងស្ថិតនៅភូមិអូរតាពូង ឃុំកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ធ្នើរ (ពីលោហធាតុកែច្នៃ) | ៣១០០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំ ស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ពីលោហធាតុកែច្នៃ (ធ្នើរ) ប្រាយម៍ ស្តរេច សីលូសិន (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហ៊ែង សុខគង់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តកំពង់ស្ពឺ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
- រដ្ឋបាលស្រុកគងពិសី
- រដ្ឋបាលឃុំកោរកោះ

"ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤១៤ ឧវបន.ឧសក.គក.ផលក

ថ្ងៃ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៧ ឆ្នាំ២០២៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៣១៩៧/២៣ ក.អ.ក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតរោងចក្រផលិត និងផ្គុំដំឡើងឧបករណ៍ជាង របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិត និងផ្គុំដំឡើងឧបករណ៍ជាង ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ដាប់បែលយូដាប់បែលយូ ធូល អិលអិលស៊ី ឯ.ក

## សម្រេច

**ប្រការ១:** អនុញ្ញាតឱ្យក្រុមហ៊ុន **ដាប់បែលយូដាប់បែលយូ ធូល អិលអិលស៊ី ឯ.ក (WW TOOLS LLC CO., LTD.)** តំណាងដោយលោកស្រី **TAN, LANFANG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **E16362261** ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ បង្កើតរោងចក្រ**ផលិត និងផ្គុំដំឡើងឧបករណ៍ជាង** ដែលមានទីតាំងស្ថិតនៅ**ភូមិអូរស្នោ ឃុំស្នុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។**

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-ឧបករណ៍ជាង (Socket) | ២៧៣៣ |
| ២-ឧបករណ៍ជាង (Work Table & Tool Cart) | ៣១០០ |
| ៣-ឧបករណ៍ជាង (Garden Cart, Hand Truck, Wheel Barrow) | ២៨១៦ |
| ៤-ឧបករណ៍ជាង (Tire) | ២២១១ |
| ៥-ឧបករណ៍ជាង (Hose Reel, Air Hose) | ២២១៩ |
| ៦-ឧបករណ៍ជាង (Brush) | ៣២៩០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិត និងផ្គុំដំឡើងឧបករណ៍ជាង ដាប់បែលយូដាប់បែលយូ ធូល អិលអិលស៊ី ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

